| ៤១. អនុប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ក្រសួងកិច្ចការនារី | សមាជិក |
| ៤២. អនុប្រធាននាយដ្ឋានស្ថិតិសេដ្ឋកិច្ច ក្រសួងផែនការ | សមាជិក |
| ៤៣. អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច ក្រសួងផែនការ | សមាជិក |
| ៤៤. អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច ក្រសួងផែនការ | សមាជិក |
| ៤៥. អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច ក្រសួងផែនការ | សមាជិក |
| ៤៦. អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច ក្រសួងផែនការ | សមាជិក |
| ៤៧. ប្រធានការិយាល័យផែនការ និងព័ត៌មានពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤៨. អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច ក្រសួងផែនការ | សមាជិក |
| ៤៩. អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច និងជាទីប្រឹក្សាក្រសួងផែនការ | សមាជិក |

## សមាសភាពគណៈកម្មាធិការជំរឿនសេដ្ឋកិច្ចនៅរាជធានីខេត្ត ឆ្នាំ២០២២

| | |
|---|---|
| ១. អភិបាលរាជធានី ខេត្ត | ប្រធាន |
| ២. អភិបាលរងរាជធានី ខេត្ត | អនុប្រធាន |
| ៣. ប្រធានមន្ទីរផែនការរាជធានី ខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| ៤. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | សមាជិក |
| ៥. ស្នងការនគរបាលរាជធានី ខេត្ត | សមាជិក |
| ៦. ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី/ខេត្ត | សមាជិក |
| ៧. ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត | សមាជិក |
| ៨. ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត | សមាជិក |
| ៩. ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត | សមាជិក |
| ១០. ប្រធានសាខាពន្ធដាររាជធានី ខេត្ត | សមាជិក |
| ១១. ប្រធានឧទ្ទកាល័យសាលារាជធានី ខេត្ត | សមាជិក |
| ១២. តំណាងម្នាក់ពីវិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ១៣. អនុប្រធានមន្ទីរផែនការរាជធានី ខេត្ត ទទួលបន្ទុកការិយាល័យស្ថិតិ | លេខាធិការ |

## សមាសភាពគណៈកម្មាធិការជាតិសម្រាប់យុទ្ធនាការឃោសនាព័ត៌មានជំរឿនសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២

| | |
|---|---|
| ១. រដ្ឋលេខាធិការប្រចាំការ ក្រសួងផែនការ | ប្រធាន |
| ២. រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | អនុប្រធាន |
| ៣. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | អនុប្រធាន |
| ៤. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | សមាជិកអចិន្ត្រៃយ៍ |
| ៥. អគ្គនាយកវិទ្យុជាតិ | សមាជិក |
| ៦. តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៧. តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨. តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៩. តំណាងក្រសួងធម្មការ និងសាសនា | សមាជិក |
| ១០. តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១១. តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១២. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៤. តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៥. ប្រធានសមាគមអ្នកសារព័ត៌មានកម្ពុជា | សមាជិក |
| ១៦. តំណាងក្រុមហ៊ុនទូរស័ព្ទចល័ត Vietel | សមាជិក |
| ១៧. តំណាងសារព័ត៌មានខ្មែរ | សមាជិក |
| ១៨. តំណាងក្រុមហ៊ុនទូរស័ព្ទចល័ត Mobitel | សមាជិក |
| ១៩. តំណាងក្រុមហ៊ុនទូរស័ព្ទចល័ត Smart | សមាជិក |
| ២០. អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | លេខាធិការ |
| ២១. ប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | ជំនួយការ |

# ផែនទីនៃព្រះរាជាណាចក្រកម្ពុជា តាមរាជធានីខេត្ត



# តួលេខសង្ខេប

| | |
|---|---|
| រាជធានីភ្នំពេញ | 1 |
| ចំនួនខេត្ត | 24 |
| ចំនួនស្រុក/ខណ្ឌ | 204 |
| ចំនួនឃុំ/សង្កាត់ | 1,652 |
| ចំនួនភូមិ[3] | 14,563 |
| សរុបចំនួនអង្គភាពសេដ្ឋកិច្ច | 753,670 |
| ៥នាក់ និងច្រើនជាង | 53,724 |
| ១០នាក់ និងច្រើនជាង | 20,820 |
| ៥០នាក់ និងច្រើនជាង | 3,519 |
| ១០០នាក់ និងច្រើនជាង | 1,870 |
| ៥០០នាក់ និងច្រើនជាង | 624 |
| អ្នកតំណាងជាស្ត្រី (%) | 69.1 |
| ទីប្រជុំជន (%) | 52.5 |
| ទីជនបទ (%) | 47.5 |
| ចំនួនអ្នកចូលរួមការងារ | 2,980,569 |
| បុរសចំនួន | 1,139,207 |
| ស្ត្រីចំនួន | 1,841,362 |
| ចំនួនអ្នកចូលរួមការងារជាមធ្យមសម្រាប់មួយអង្គភាពសេដ្ឋកិច្ច | 4 |
| ចំនួនអង្គភាពសេដ្ឋកិច្ចជាមធ្យមសម្រាប់មួយគីឡូម៉ែត្រការ៉េ (Kម$^{២}$) | 4 |
| ចំនួនអង្គភាពសេដ្ឋកិច្ចក្នុងចំនួនបុគ្គលិក ១០០០នាក់ | 45 |
| ចំនួនប្រជាជន[4] សម្រាប់មួយអង្គភាពសេដ្ឋកិច្ច | 22 |
| ចំនួនអង្គភាពសេដ្ឋកិច្ចសម្រាប់ក្នុង១០០០គ្រួសារ | 198 |
| ចំនួនគ្រួសារសម្រាប់អង្គភាពសេដ្ឋកិច្ចមួយ | 5 |
| ចំនួនអង្គភាពសេដ្ឋកិច្ចថ្មី [5)] | 241,821 |

*3 ចំនួនខេត្ត ក្រុង ស្រុក ខណ្ឌ សង្កាត់ ឃុំ និងភូមិ គឺយកពីរបាយការណ៍ជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយឆ្នាំ២០១៩*

*4 ទំហំនៃចំនួនប្រជាជន និងចំនួនគ្រួសារ គឺផ្អែកលើទិន្នន័យមូលដ្ឋានឃុំ (CDB) ឆ្នាំ២០២១*

*5) "អង្គភាពសេដ្ឋកិច្ចថ្មី" បានន័យថាជាអង្គភាពដែលចាប់ផ្តើមអាជីវកម្មនៅចន្លោះថ្ងៃទី១ ខែមករា ឆ្នាំ២០២០ និងនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២២*

| | |
|---|---|
| ចំណូលពីការលក់ជាមធ្យមប្រចាំឆ្នាំ ( លានដុល្លារអាមេរិក ) | 50,686 |
| ចំណូលពីការលក់ជាមធ្យមប្រចាំឆ្នាំសម្រាប់អង្គភាពសេដ្ឋកិច្ចមួយ ( ដុល្លារអាមេរិក ) [6)] | 67,252 |
| ការចំណាយជាមធ្យមប្រចាំឆ្នាំ ( លានដុល្លារសហរដ្ឋអាមេរិក ) | 38,614 |
| ការចំណាយជាមធ្យមប្រចាំឆ្នាំសម្រាប់អង្គភាពសេដ្ឋកិច្ចមួយ ( ដុល្លារអាមេរិក ) [7)] | 51,236 |
| | |
| ប្រាក់ចំណេញ និងខាតប្រចាំឆ្នាំ ( លានដុល្លារអាមេរិក ) | 120,71 |
| ប្រាក់ចំណេញ និងខាត សម្រាប់អង្គភាពសេដ្ឋកិច្ចមួយ ( ដុល្លារអាមេរិក ) [8)] | 16,016 |

**សម្គាល់៖** រាល់ទិន្នន័យ តួលេខបង្ហាញនៅក្នុងរូបភាព និងផែនទី តារាងទិន្នន័យអំពីអង្គភាពសេដ្ឋកិច្ច និងតារាងទិន្នន័យអំពីអ្នកចូលរួមការងារ គឺត្រូវបានបង្ហាញជា "លេខឡាតាំង" ដើម្បីរក្សាភាពដើមនៃទិន្នន័យព័ត៌មានពីកម្មវិធីវិភាគស្ថិតិសម្រាប់របាយការណ៍លទ្ធផលជាភាសាខ្មែរ និង អង់គ្លេស។

[6] *) រាប់បញ្ចូលតម្លៃសន្មត់សម្រាប់អង្គភាពសេដ្ឋកិច្ចដែលតម្លៃចំណូលពីការលក់ស្មើ 0 ឬ "មិនត្រូវបានរាយការណ៍អំពីចំណូល"*

[7] *) រាប់បញ្ចូលតម្លៃសន្មត់សម្រាប់អង្គភាពសេដ្ឋកិច្ចដែលមានតម្លៃចំណាយស្មើ 0 ឬ "មិនត្រូវបានរាយការណ៍អំពីការចំណាយ"*

[8] *) រាប់បញ្ចូលតម្លៃសន្មត់សម្រាប់អង្គភាពសេដ្ឋកិច្ចដែលមានតម្លៃចំណូលពីការលក់ និង/ឬ តម្លៃចំណាយ ស្មើ 0 ឬ "មិនត្រូវបានរាយការណ៍អំពីចំណូល ឬចំណាយ"*

# ផ្នែក១

# ការធ្វើជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២

**សម្គាល់៖** រាល់ទិន្នន័យ តួលេខបង្ហាញនៅក្នុងរូបភាព និងផែនទី តារាងទិន្នន័យអំពីអង្គភាពសេដ្ឋកិច្ច និងតារាងទិន្នន័យអំពីអ្នកចូលរួមការងារ និងតួលេខទិន្នន័យផ្សេងៗទៀត គឺត្រូវបានបង្ហាញជា "**លេខឡាតាំង**" ដើម្បីរក្សាភាពដើមនៃទិន្នន័យព័ត៌មានពីកម្មវិធីវិភាគស្ថិតិ សម្រាប់របាយការណ៍លទ្ធផលជាភាសាខ្មែរ និង អង់គ្លេស។

# ការធ្វើជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២២

## ១. គោលបំណង

១).បង្កើតនូវបញ្ជីមេអង្គភាពសេដ្ឋកិច្ចដ៏ទូលំទូលាយថ្នាក់ជាតិមួយ សម្រាប់ការប្រើប្រាស់ធ្វើអង្កេតសហគ្រាស និងការធ្វើជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២២ ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យលេខ១៥១ អនក្រ.បក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំនិងការប្រព្រឹត្តទៅនៃជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២១។

២). ផលិតទិន្នន័យស្ថិតិបែងចែកអង្គភាពសេដ្ឋកិច្ច និងចំនួនបុគ្គលិកចូលរួមការងារ ទៅតាមលក្ខណៈផ្សេងៗរបស់អង្គភាពសេដ្ឋកិច្ច ដូចជាការបែងចែកតាមវិស័យ ទំហំ លក្ខណៈទ្រង់ទ្រាយ និងតាមតំបន់ផ្សេងៗ។

៣). ធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានស្ថិតិអំពីសកម្មភាពអាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម និងសេវាកម្មផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២. កាលបរិច្ឆេទយោងនៃជំរឿនសេដ្ឋកិច្ច

កំណត់យកថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ជាកាលបរិច្ឆេទយោង។

## ៣. រយៈពេលធ្វើសម្ភាសន៍

ចាប់ពីថ្ងៃទី០១ ខែមីនា រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (រយៈពេលមួយខែ)។

## ៤. បទប្បញ្ញត្តិនៃជំរឿនសេដ្ឋកិច្ច

ជំរឿនត្រូវបានធ្វើឡើង ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិខាងក្រោម៖

- មាត្រា ៨ និង ៩ នៃច្បាប់ស្តីពីស្ថិតិរបស់ប្រទេសកម្ពុជា
- អនុក្រឹត្យលេខ១៥១អនក្រ.បក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩

## ៥. វិសាលភាពនៃជំរឿនសេដ្ឋកិច្ច

ជំរឿនសេដ្ឋកិច្ចត្រូវបានអនុវត្តគ្រប់អង្គភាពសេដ្ឋកិច្ចទាំងអស់ ដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមកាលបរិច្ឆេទដែលបានកំណត់គឺថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។ អង្គភាពសេដ្ឋកិច្ចទាំងអស់ ត្រូវបានរាប់បញ្ចូលរួមទាំងផ្សារ រោងចក្រ ក្រុមហ៊ុន សិប្បកម្ម ការលក់ទំនិញតាមប្រព័ន្ធអនឡាញ និង សេវាកម្ម សាលារៀន សកលវិទ្យាល័យ វត្តអារាម វិហារសាសនា មន្ទីរពេទ្យ គ្លីនិកឯកជន និងមណ្ឌលសុខភាព ជាដើម។

ទោះជាយ៉ាងណាក៏ដោយ ជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ មិនត្រូវបានរាប់បញ្ចូលចំពោះអង្គភាពសេដ្ឋកិច្ចដែលស្ថិតក្នុងចំណាត់ថ្នាក់ផ្នែក A (អង្គភាពកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) និងផ្នែក T (សកម្មភាពការងារបំរើឱ្យគ្រួសារ)នៃចំណាត់ថ្នាក់ឧស្សាហកម្មតាមស្តង់ដារអន្តរជាតិ (ISIC Rev4) និងអង្គភាពសេដ្ឋកិច្ចមួយចំនួនផ្សេងទៀត ដែលមិនត្រូវបានបញ្ចូលក្នុងការធ្វើជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ ដូចជាអង្គភាពសេដ្ឋកិច្ចចល័ត ក្រសួងស្ថាប័ន ឬអង្គភាពរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ទីបញ្ជាការដ្ឋានទាហាន និងព្រមទាំងអង្គទូត ដូចជាស្ថានទូត និងស្ថានកុងស៊ុល និងអនុព័ន្ធយោធា ជាដើម។

## ៦. ឯកត្តាមណ្ឌលជំរឿន

យោងតាមនាយកដ្ឋានកិច្ចការផ្នែកស្ថិតិសេដ្ឋកិច្ច និងសង្គមកិច្ច របស់អង្គការសហប្រជាជាតិ( UNDESA )។ អង្គភាពសេដ្ឋកិច្ចមួយ ក៏ដូចជាមណ្ឌលជំរឿនសម្រាប់ធ្វើជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ ត្រូវបានកំណត់និយមន័យដូចខាងក្រោមៈ

**"អង្គភាពសេដ្ឋកិច្ច គឺអង្គភាពអាជីវកម្ម ឬជាផ្នែកមួយនៃអង្គភាពអាជីវកម្ម ដែលមានទីតាំងមួយជាក់លាក់ ហើយនិងមានសកម្មភាពផលិតកម្មតែមួយ (មិនមែនជាសម្ព័ន្ធ) ឬមានសកម្មភាពផលិតកម្មចម្បងដែលបង្កើតតម្លៃបន្ថែមភាគច្រើនបំផុត"។**

## ៧. ព័ត៌មានទិន្នន័យដែលត្រូវប្រមូល

១. ឈ្មោះ អាស័យដ្ឋាន និងលេខទូរស័ព្ទ របស់អង្គភាពសេដ្ឋកិច្ច ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង
២. ភេទនៃអ្នកតំណាងអង្គភាពសេដ្ឋកិច្ច និង សញ្ជាតិនៃម្ចាស់អង្គភាពសេដ្ឋកិច្ច
៣. ការចុះបញ្ជីអង្គភាពសេដ្ឋកិច្ច (ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មខេត្ត)
៤. ឈ្មោះក្រសួងឬទីភ្នាក់ងារដែលបានចេញអាជ្ញាប័ណ្ណ ឬការផ្លាស់កម្មសិទ្ធិសម្រាប់ប្រតិបត្តិការអាជីវកម្ម
៥. ប្រភេទនៃភាពជាម្ចាស់(កម្មសិទ្ធិផ្តាច់មុខ ភាពជាដៃគូ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតផ្សេងៗទៀត)។
៦. រចនាសម្ព័ន្ធរបស់អង្គភាពសេដ្ឋកិច្ច (អង្គភាពសេដ្ឋកិច្ចទោល ទីស្នាក់ការកណ្តាល ឬជាសាខា)
៧. ការកាន់កាប់ និងទីកន្លែងអាជីវកម្ម (ប្រភេទ និងផ្ទៃក្រឡាទីកន្លែងអាជីវកម្ម)
៨. ម៉ោងបើកធ្វើអាជីវកម្ម
៩. ឆ្នាំចាប់ផ្តើមធ្វើអាជីវកម្ម
១០.ចំនួនអ្នកចូលរួមការការងារតាមភេទ ស្ថានភាពការងារ និងសញ្ជាតិ(១សប្តាហ៍មុនថ្ងៃទី១ ខែមីនា ឆ្នាំ២០២២)
១១.សកម្មភាពអាជីវកម្មចម្បងនៃការិយាល័យកណ្តាល (ចំណាត់ថ្នាក់វិស័យឧស្សាហកម្ម "ISIC Rev4")
១២.ចំនួនការិយាល័យសាខា បើសិនមាន
១៣.សរុបចំនួននិយោជិតបុគ្គលិកកម្មករអចិន្ត្រៃយ៍ចូលរួមការងារជាប្រចាំ (នៅដំណាច់ខែធ្នូ ឆ្នាំ២០២១)
១៤.សកម្មភាពអាជីវកម្មចម្បង និងសកម្មភាពអាជីកម្មបន្ទាប់បន្សំរបស់អង្គភាពសេដ្ឋកិច្ចនៅទីស្នាក់ការកណ្តាល និងសាខា (ផ្អែកតាមចំណាត់ថ្នាក់វិស័យឧស្សាហកម្ម "ISIC Rev4")
១៥. អង្គភាពសេដ្ឋកិច្ចដែលមានបញ្ជីគណនេយ្យ (តារាងតុល្យការ និង របាយការណ៍ចំណូល និងចំណាយ)
១៦. ចំណូលពីការលក់ និងចំណាយប្រតិបត្តិការ ប្រាក់ឈ្នួល/ប្រាក់ខែ(ប្រចាំថ្ងៃ/ខែ) និង ចំនួនថ្ងៃធ្វើការ (ក្នុងខែកុម្ភៈ ឆ្នាំ២០២២)
១៧. សរុបទ្រព្យសកម្ម នៅដំណាច់ខែធ្នូ ឆ្នាំ២០២១
១៨. សរុបទ្រព្យមូលធន នៅដំណាច់ខែធ្នូ ឆ្នាំ២០២១
១៩. សរុបបំណុលរយៈពេលវែង នៅដំណាច់ខែធ្នូ ឆ្នាំ២០២១
២០.សរុបបំណុលចរន្ត(រយៈពេលខ្លី) នៅដំណាច់ខែធ្នូ ឆ្នាំ២០២១
២១.សរុបចំណូល និងចំណាយ នៅក្នុងឆ្នាំ២០២១
២២.ប្រតិបត្តិការអាជីវកម្មតាមអនឡាញ និងផលប៉ះពាល់ពីជំងឺកូវីដ១៩ (Covid-19)

## ៨. រចនាសម្ព័ន្ធគ្រប់គ្រងប្រតិបត្តិការជំរឿនសេដ្ឋកិច្ច

១. ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

២. មន្ត្រីសម្របសម្រួលរាជធានី ខេត្ត (ប្រធានមន្ទីរផែនការរាជធានី ខេត្តទាំង២៥) មាន ១៣៥ នាក់

៣. មន្ត្រីត្រួតពិនិត្យការសម្ភាសន៍(ភាគច្រើនមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ) មាន ៤៩៩ នាក់

៤. មន្ត្រីសម្ភាសន៍ (មន្ត្រីនៅរាជធានីខេត្ត និងក្រុង/ស្រុក/ខណ្ឌ) មាន ៥៣២៦ នាក់

៥. ការបណ្តុះបណ្តាលមន្ត្រីប្រមូលជំរឿនត្រូវបានធ្វើចាប់ពីខែកុម្ភៈ ឆ្នាំ២០២២

## ៩. វិធីសាស្ត្រនៃការធ្វើជំរឿនសេដ្ឋកិច្ច

១).មន្ត្រីសម្ភាសន៍ត្រូវចុះទៅសម្ភាសន៍ផ្ទាល់គ្រប់អង្គភាពសេដ្ឋកិច្ចទាំងអស់នៅក្នុងមណ្ឌលជំរឿន ហើយនិងមន្ត្រីជំរឿនសេដ្ឋកិច្ច ត្រូវអនុវត្តតាមវិធីសាស្ត្រណែនាំមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យការសម្ភាស។ មន្ត្រីសម្ភាសន៍ត្រូវសម្ភាសន៍ម្ចាស់អង្គភាពសេដ្ឋកិច្ច ឬអ្នកគ្រប់គ្រងអង្គភាពសេដ្ឋកិច្ច ឬអ្នកតំណាងទទួលការងារជំនួសម្ចាស់អង្គភាពសេដ្ឋកិច្ច ហើយត្រូវសម្ភាសន៍ និងបំពេញតារាងសំណួរអង្គភាពសេដ្ឋកិច្ច។

២).បន្ថែមលើសពីនេះ គឺម្ចាស់អង្គភាពសេដ្ឋកិច្ចអាចបំពេញព័ត៌មានទិន្នន័យនៅក្នុងតារាងសំណួរដោយខ្លួនឯង មន្ត្រីជំរឿនសេដ្ឋកិច្ចអាចជួយពន្យល់ដល់ម្ចាស់អង្គភាពសេដ្ឋកិច្ច តាមសំណើរបស់ម្ចាស់អង្គភាពសេដ្ឋកិច្ច ឬតំណាង សម្រាប់ការបំពេញតារាងសំណួរដោយខ្លួនឯង។

៣).ក្នុងករណីការសម្ភាសអង្គភាពសេដ្ឋកិច្ចនៅកន្លែងមណ្ឌលជំរឿន មិនបានបញ្ចប់រហូតដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ "ក្រុមមន្ត្រីជំរឿនពិសេស" ចុះជួយសម្ភាសន៍ឱ្យបានចប់សព្វគ្រប់។

## ១០. មន្ត្រីសម្ភាសន៍

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បានជ្រើសរើសមន្ត្រីសម្ភាសន៍ចំនួន ៥.៣២៦ នាក់ សម្រាប់អនុវត្តការងារជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២។ មន្ត្រីសម្ភាសន៍ម្នាក់ៗត្រូវបានផ្តល់ឱ្យមួយភូមិ ឬពីរភូមិ ឬ មួយមណ្ឌលជំរឿន ដែលត្រូវបានកំណត់ ដើម្បីធ្វើការសម្ភាសដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំរបស់មន្ត្រីសម្ភាសន៍ដែលមាននៅក្នុងគេហទំព័រ https://nada.nis.gov.kh/index.php/nis-nada ។

## ១១. មន្ត្រីត្រួតពិនិត្យការសម្ភាស

មន្ត្រីត្រួតពិនិត្យការសម្ភាសមាន ៤៩៩នាក់ ដែលត្រូវបានជ្រើសរើសសម្រាប់អនុវត្តការងារជំរឿនសេដ្ឋកិច្ច។ មន្ត្រីត្រួតពិនិត្យ ត្រូវបានចាត់តាំងឱ្យទទួលបន្ទុកត្រួតពិនិត្យដឹកនាំមន្ត្រីសម្ភាសន៍ច្រើននាក់ ដើម្បីធ្វើការងាររបស់ពួកគេដោយផ្អែកតាមសេចក្តីណែនាំក្នុងសៀវភៅណែនាំសម្រាប់មន្ត្រីត្រួតពិនិត្យការសម្ភាសដែលអាចរកឃើញមាននៅក្នុងគេហទំព័រ https://nada.nis.gov.kh/index.php/nis-nada។

## ១២. ការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យការសម្ភាស

១).ការបណ្តុះបណ្តាលមន្ត្រីជំរឿនសេដ្ឋកិច្ច ត្រូវបានធ្វើឡើងពីរលើកនៅវិទ្យាស្ថានជាតិស្ថិតិ៖ លើកទី១ មានរយៈពេលពីរ(២)ថ្ងៃ គឺនៅថ្ងៃទី១៤ ដល់ទី១៥ ខែធ្នូ ឆ្នាំ២០២១ និង លើកទីពីរមានរយៈពេលប្រាំ(៥)ថ្ងៃ គឺនៅថ្ងៃទី១៧ ដល់ទី២១ ខែមករា ឆ្នាំ២០២២។

២).ការបណ្តុះបណ្តាលគ្រូបង្គោល ត្រូវបានរៀបចំ ដោយក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ មានរយៈពេល៥ថ្ងៃ គឺចាប់ពីថ្ងៃទី១៣ ដល់ទី១៧ ខែកុម្ភៈ ឆ្នាំ២០២២។

៣).ការបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យការសម្ភាស និងមន្ត្រីសម្ភាសន៍ ត្រូវបានធ្វើឡើងសម្រាប់រយៈពេលប្រាំថ្ងៃ គឺចាប់ពីថ្ងៃទី២០ ដល់ទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ នៅតាមរាជធានីខេត្តនីមួយៗ ដោយមានការចូលរួមពីអភិបាលស្រុក និងមេឃុំ/ចៅសង្កាត់។

៤).មន្ត្រីស្នូលបច្ចេកទេសរបស់វិទ្យាស្ថានជាតិស្ថិតិ និង គ្រូបង្គោលបណ្តុះបណ្តាលដែលត្រូវបានជ្រើសរើសពីមន្ត្រីជំនាញរបស់វិទ្យាស្ថានជាតិស្ថិតិ ត្រូវបានចាត់តាំងឱ្យទទួលការងារជាគ្រូបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍។

៥).គ្រូបង្គោលត្រូវបានឱ្យទទួលភារកិច្ចជាមន្ត្រីប្រចាំតំបន់ និងមន្ត្រីជំនួយការតំបន់ក្នុងពេលធ្វើជំរឿនសេដ្ឋកិច្ច។

## ១៣. ការគូរផែនទី

ផែនទីព្រំប្រទល់ភូមិ/មណ្ឌលជំរឿនត្រូវបានគូរដោយផ្អែកលើផែនទីភូមិសាស្ត្រជំរឿនប្រជាជនឆ្នាំ២០១៩ ដើម្បីធ្វើជាផែនទីមណ្ឌលជំរឿនសម្រាប់មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យការសម្ភាស សម្រាប់អនុវត្តដំណើរការជំរឿន។ ភូមិដែលមានអង្គភាពសេដ្ឋកិច្ចច្រើន គឺត្រូវបានបែងចែកជាមណ្ឌលជំរឿនតូចៗ។ ផែនទីមណ្ឌលជំរឿនត្រូវបានគូរជាមណ្ឌលជំរឿនតាមឯកសារណែនាំដល់មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យការសម្ភាស។

## ១៤. ការសម្ភាសន៍សាកល្បង និងធ្វើអង្កេតសាកល្បង

### ១).ការសម្ភាសសាកល្បងអំពីកម្រងតារាងសំណួរអង្គភាពសេដ្ឋកិច្ច

ក).ការសម្ភាសសាកល្បងតារាងកម្រងសំណួរអង្គភាពសេដ្ឋកិច្ច ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២២ ដល់ទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ នៅក្នុងតំបន់ភូមិសាស្ត្រ ចំនួនបីខុសគ្នា គឺនៅរាជធានីភ្នំពេញ ខេត្តស្វាយរៀង និងខេត្តតាកែវ។

ខ).ការសម្ភាសសាកល្បងកម្រងតារាងសំណួរអង្គភាពសេដ្ឋកិច្ច ត្រូវបានធ្វើក្នុងគោលបំណង ដើម្បីធ្វើតេស្តដំណើរការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនសេដ្ឋកិច្ច ដូចជា បញ្ជីអង្គភាពសេដ្ឋកិច្ច អថេរនៃតារាងសំណួរអង្គភាពសេដ្ឋកិច្ច វិធីសាស្ត្រសម្ភាសន៍ និងសេចក្តីណែនាំដែលត្រូវបានបញ្ចូលនៅក្នុងសៀវភៅណែនាំរបស់មន្ត្រីសម្ភាសន៍។

គ).លទ្ធផលការសម្ភាសន៍សាកល្បងចុងក្រោយត្រូវបានប្រើប្រាស់សម្រាប់បង្កើតផែនការសមស្របសម្រាប់ជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២។

### ២).ការធ្វើអង្កេតសាកល្បង (Pilot Survey)

ក).ការអង្កេតសាកល្បង គឺត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ដល់ទី១២ ខែធ្នូ ឆ្នាំ២០២១ មានសំណាកគំរូចំនួន១០០ភូមិ/មណ្ឌលជំរឿន ដែលត្រូវបានជ្រើសរើសសំណាកគំរូពីគ្រប់រាជធានី ខេត្តទាំងអស់។

ខ).លើសពីនេះ អង្គភាពសេដ្ឋកិច្ចខ្នាតធំៗទាំងអស់ (ដែលមានអ្នកចូលរួមការងារចាប់ពី១០០នាក់ និងច្រើនជាង) ត្រូវបានសម្ភាសន៍ទាំងអស់នៅក្នុងភូមិ/មណ្ឌលសម្ភាសន៍។

គ).គោលបំណងនៃការធ្វើអង្កេតសាកល្បង រួមមានៈ

១).ដើម្បីសាកល្បងបញ្ជីកម្រងសំណួរ និងឯកសារផ្សេងទៀតនៃសេចក្តីព្រាងចុងក្រោយ សម្រាប់ដំណើរការជំរឿនសេដ្ឋកិច្ចឱ្យរលូន

២).ដើម្បីសាកល្បងនីតិវិធីការងារនៅគ្រប់ដំណាក់កាលជំរឿនសេដ្ឋកិច្ច របស់មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ មន្ត្រីប្រចាំតំបន់ មន្ត្រីជំនួយការតំបន់ទាំងអស់ និងមន្ត្រីជំនាញរបស់វិទ្យាស្ថានជាតិស្ថិតិ។

៣).ដើម្បីសាកល្បងលើវិធីសាស្ត្រផលិតតារាងទិន្នន័យស្ថិតិ សម្រាប់របាយការណ៍លទ្ធផលជំរឿនសេដ្ឋកិច្ច

៤).ដើម្បីទទួលបានទិន្នន័យអំពីអង្គភាពសេដ្ឋកិច្ចខ្នាតតូច មធ្យម និងធំ ហើយនិងអង្គភាពសេដ្ឋកិច្ចកម្រិតមីក្រូផ្សេងៗទៀត។

## ១៥. ការបញ្ជូនឯកសារជំរឿនសេដ្ឋកិច្ច

១).មន្ត្រីសម្ភាសន៍ត្រូវបញ្ជូនឯកសារជំរឿន រួមទាំងតារាងសំណួរអង្គភាពសេដ្ឋកិច្ច និងឯកសារពាក់ព័ន្ធការងារជំរឿនផ្សេងទៀត ដែលបានពិនិត្យដោយមន្ត្រីត្រួតពិនិត្យ បញ្ជូនឱ្យបានមុនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២។

២).ចុងក្រោយមន្ត្រីជំរឿនសេដ្ឋកិច្ចរាជធានីខេត្ត បានបញ្ជូនឯកសារទាំងអស់ទៅឱ្យមន្ត្រីគ្រប់គ្រងជំរឿនសេដ្ឋកិច្ចនៅវិទ្យាស្ថានជាតិស្ថិតិ ឱ្យបានមុនថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ បន្ទាប់ពីបានពិនិត្យរួច។

## ១៦. ការរៀបចំតារាង និងការប្រព្រឹត្តកម្មទិន្នន័យ

### ១).លទ្ធផលបឋមនៃជំរឿនសេដ្ឋកិច្ច

ទិន្នន័យនៃបញ្ជីអង្គភាពសេដ្ឋកិច្ច និងតារាងទិន្នន័យសង្ខេបត្រូវបានពិនិត្យ និងបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រចប់ជាស្ថាពរនៅវិទ្យាស្ថានជាតិស្ថិតិ ហើយត្រូវផលិតតារាងលទ្ធផលបឋមនៃជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២។ ការចងក្រងតារាងទិន្នន័យជំរឿនសេដ្ឋកិច្ច បានបង្ហាញអំពីលទ្ធផលបឋមនៃជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២។

### ២).លទ្ធផលចុងក្រោយនៃជំរឿនសេដ្ឋកិច្ច

ក).ការងារប្រព្រឹត្តកម្មទិន្នន័យ និងការដាក់លេខកូដទិន្នន័យតាមវិស័យ ត្រូវបានធ្វើនៅវិទ្យាស្ថានជាតិស្ថិតិ ដោយបែងចែកតាមរាជធានី ខេត្តនីមួយៗ បន្ទាប់ពីវិទ្យាស្ថានជាតិស្ថិតិ បានទទួលតារាងសំណួរអង្គភាពសេដ្ឋកិច្ច និងឯកសារពាក់ព័ន្ធផ្សេងៗសម្រាប់ជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២។ ឯកសារទាំងអស់ត្រូវបានរក្សាទុកនៅកន្លែងផ្ទុកឯកសារនៅក្នុងឃ្លាំងនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។

ខ).ការបញ្ចូលទិន្នន័យត្រូវបានធ្វើឡើងនៅវិទ្យាស្ថានជាតិស្ថិតិដោយបញ្ចូលមួយខេត្តម្តងៗ និងបន្ទាប់មក គឺត្រូវធ្វើការកែសម្រួលទិន្នន័យតាមកម្មវិធីកុំព្យូទ័រ និងការងារសម្អាតទិន្នន័យត្រូវបានធ្វើនៅពេលដែលផលិតតារាងទិន្នន័យស្ថិតិជំរឿនសេដ្ឋកិច្ច។

### ៣).ការវិភាគលទ្ធផលជំរឿនសេដ្ឋកិច្ច

វិភាគរបាយការណ៍លទ្ធផលទិន្នន័យជំរឿនសេដ្ឋកិច្ច ត្រូវបានធ្វើឡើងតាមបែបទម្រង់ទិដ្ឋភាពផ្សេងៗ នៃតម្រូវការប្រើប្រាស់ទិន្នន័យ។

៤).ផែនទី Atlas នៃទិន្នន័យជំរឿនសេដ្ឋកិច្ច

ផែនទីបង្ហាញទិន្នន័យស្ថិតិសម្រាប់ប្រទេសកម្ពុជា និងផែនទីសម្រាប់រាជធានីខេត្តនីមួយៗ ត្រូវបានផលិតនៅក្នុងរបាយការណ៍លទ្ធផលនៃជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២។

៥).បញ្ជីអង្គភាពសេដ្ឋកិច្ច

សំណុំទិន្នន័យ(Dataset)ដែលមានព័ត៌មានអំពីអង្គភាពសេដ្ឋកិច្ច(សហគ្រាស) និងលេខកូដតំបន់ភូមិសាស្ត្ររដ្ឋបាល ត្រូវបានរៀបចំជាបញ្ជីអង្គភាពសេដ្ឋកិច្ច សម្រាប់ការជ្រើសរើសសំណាកគំរូនៅក្នុងការអង្កេតសហគ្រាស និងការប្រើប្រាស់ធ្វើអង្កេតអាជីវកម្មផ្សេងៗទៀត។

## ១៧. ការផ្សព្វផ្សាយទិន្នន័យជំរឿនសេដ្ឋកិច្ច

លទ្ធផលនៃជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ តាមរយៈសិក្ខាសាលា និងប្រព័ន្ធផ្សព្វផ្សាយ ដែលមានដូចជា ការសែត និងប្រព័ន្ធអ៊ីនធឺណែត តាមការបរិច្ឆេទដូចខាងក្រោម៖

១).លទ្ធផលបឋមត្រូវបានផ្សព្វផ្សាយនៅខែមករា ឆ្នាំ២០២៣

២).លទ្ធផលចុងក្រោយនៃជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២ នឹងត្រូវផ្សព្វផ្សាយនៅខែតុលា ឆ្នាំ២០២៣

## ១៨. ការផលិតតារាងស្ថិតិ

១).តារាងទិន្នន័យស្ថិតិជំរឿនសេដ្ឋកិច្ច ត្រូវបានផលិតបែងចែកតាមក្រុមប្រធានបទ និងតាមទំហំនៃអ្នកចូលរួមការងារ ភេទអ្នកតំណាង សកម្មភាពសេដ្ឋកិច្ច និងរាជធានី ខេត្ត។

២).ចំនួននៃអ្នកចូលរួមការងារជាមធ្យមក្នុងអង្គភាពសេដ្ឋកិច្ចមួយ ចំណូលពីការលក់ជាមធ្យម និងការចំណាយប្រតិបត្តិការជាមធ្យម សម្រាប់អង្គភាពសេដ្ឋកិច្ច ឬសហគ្រាសមួយ។

## ១៩. ការរក្សាសុវត្ថិភាពនៃបញ្ជីសំណួរជំរឿន និងឯកសារពាក់ព័ន្ធផ្សេងៗ

បញ្ជីសំណួរជំរឿនអង្គភាពសេដ្ឋកិច្ច និងឯកសារពាក់ព័ន្ធផ្សេងៗ ត្រូវបានរក្សាទុកក្នុងលក្ខណៈសមស្របនៅគ្រប់ដំណាក់កាលពីមន្ត្រីសម្ភាសន៍ មន្ត្រីត្រួតពិនិត្យការសម្ភាសនៅតាមការិយាល័យរដ្ឋាភិបាលក្នុងតំបន់រាជធានី ខេត្ត និងនៅវិទ្យាស្ថានជាតិស្ថិតិ ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិ មាត្រា២២ សម្រាប់ក្នុងគោលបំណងស្ថិតិតែប៉ុណ្ណោះ។

## ២០. ការធ្វើអង្កេតក្រោយជំរឿនសេដ្ឋកិច្ច

១. ការអង្កេតក្រោយជំរឿនត្រូវបានធ្វើឡើងនៅក្នុងខែឧសភា ឆ្នាំ២០២២ ដែលមានសំណាកគំរូចំនួន១០០ភូមិ ដោយអនុវត្តតាមទ្រឹស្តីនៃការជ្រើសរើសសំណាកគំរូ ដើម្បីវិភាគអំពីកម្រិតលំអៀងស្ថិតិ នៃវិសាលភាពគ្របដណ្តប់ និងកម្រិតលំអៀងមាតិកានៃអថេរជំរឿនសេដ្ឋកិច្ច។

២. ការអង្កេតចន្លោះជំរឿនសេដ្ឋកិច្ច(CIES) គ្រោងនឹងធ្វើនៅខែមីនា ឆ្នាំ២០២៦ ដោយផ្អែកលើបញ្ជីអង្គភាពសេដ្ឋកិច្ចដែលបានផលិតទិន្នន័យពីទិន្នន័យជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២។ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យ អំពីសកម្មភាពសេដ្ឋកិច្ចរបស់អង្គភាពសេដ្ឋកិច្ច ឬសហគ្រាសទាំងអស់នៅក្នុងប្រទេសកម្ពុជា និងកសាងសមត្ថភាពក្នុងការធ្វើជំរឿនសេដ្ឋកិច្ច និងការងារអង្កេតសហគ្រាស។

# ការពន្យល់ពាក្យគន្លឹះបច្ចេកទេស

*លេខនៅក្នុងវង់ក្រចក គឺជាលេខសំណួរដែលមានក្នុងតារាងសំណួរអង្គភាពសេដ្ឋកិច្ចនៃជំរឿនសេដ្ឋកិច្ច*

## អង្គភាពសេដ្ឋកិច្ច

អង្គភាពសេដ្ឋកិច្ច គឺសំដៅលើអង្គភាពអាជីវកម្ម ឬសហគ្រាស ដែលកាន់កាប់អគារ បរិវេណ ឬកន្លែងជាក់លាក់ណាមួយសម្រាប់អនុវត្តសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន និងបំពេញតាមលក្ខខណ្ឌតាមគោលការណ៍ដូចខាងក្រោម៖

(១) អង្គភាពសេដ្ឋកិច្ចគឺជាអង្គភាពមួយដែលមានទីតាំងជាក់លាក់សម្រាប់ប្រកបមុខរបរ (មួយកន្លែង) និងមានសកម្មភាពសេដ្ឋកិច្ចត្រូវបានអនុវត្តស្ថិតក្រោមការគ្រប់គ្រងតែម្នាក់។

(២) អង្គភាពសេដ្ឋកិច្ចមួយមានអ្នកចូលរួមការងារ (ម្នាក់) ឬ (ច្រើន) និង សម្ភារបរិក្ខាផលិតកម្ម និង/ឬលក់ទំនិញ ឬផ្តល់សេវាកម្ម មានមូនដ្ឋានជាបន្តបន្ទាប់។

អង្គភាពសេដ្ឋកិច្ច គឺជាអង្គភាពអាជីវកម្មមួយ ឬផ្នែកនៃអង្គភាពអាជីវកម្មដែលមានទីតាំងជាក់លាក់មួយ និងមានសកម្មភាពផលិតតែមួយ(មិនមែនជាសម្ព័ន្ធ)ឬមានសកម្មភាពផលិតកម្មសំខាន់ដែលបានបង្កើតតម្លៃបន្ថែមមួយផ្នែកធំ។ អង្គភាពសេដ្ឋកិច្ច ត្រូវបានធ្វើចំណាត់ថ្នាក់វិស័យ ដោយអនុលោមតាមចំណាត់ថ្នាក់វិស័យឧស្សាហកម្មស្តង់ដារអន្តរជាតិរបស់អង្គការសហប្រជាជាតិ ហៅកាត់ ISIC Rev.4។

ជាទូទៅ អង្គភាពសេដ្ឋកិច្ចមានបីប្រភេទ៖ អង្គភាពសេដ្ឋកិច្ចដែលមានទីតាំងជាក់លាក់ អង្គភាពសេដ្ឋកិច្ចដែលអាចផ្លាស់ប្តូរទីកន្លែងបាន និងអង្គភាពសេដ្ឋកិច្ចចល័ត។ **អង្គភាពសេដ្ឋកិច្ចដែលមានទីតាំងជាក់លាក់** គឺសំដៅលើអង្គភាពសេដ្ឋកិច្ចដែលមានសកម្មភាពអាជីវកម្មស្ថិតនៅទីតាំងជាក់លាក់ និងមានអគារ។ **អង្គភាពសេដ្ឋកិច្ចដែលផ្លាស់ប្តូរទីកន្លែង** សំដៅលើអង្គភាពសេដ្ឋកិច្ចដែលមានដំណើរការសកម្មភាពអាជីវកម្មជាប្រចាំ និងស្ថិតនៅទីតាំងជាក់លាក់មួយ ប៉ុន្តែអង្គភាពសេដ្ឋកិច្ចនោះ អាចធ្វើការផ្លាស់ប្តូរទៅទីកន្លែងផ្សេងបានយ៉ាងស្រួល។ **អង្គភាពសេដ្ឋកិច្ចចល័ត** គឺសំដៅលើអង្គភាពសេដ្ឋកិច្ចដែលមានដំណើរការធ្វើសកម្មភាពអាជីវកម្មគ្មានទីតាំងជាក់លាក់(អាជីវកម្មចល័ត)។ នៅក្នុងលទ្ធផលនៃជំរឿនសេដ្ឋកិច្ច គួរតែបញ្ចូលទិន្នន័យអង្គភាពសេដ្ឋកិច្ចចល័ត ឬ អង្គភាពសេដ្ឋកិច្ចតាមចិញ្ចើមផ្លូវនៅក្នុងរបាយការណ៍លទ្ធផលផងដែរ។

## វិសាលភាពនៃជំរឿនសេដ្ឋកិច្ច

ការធ្វើជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២២ មានវិសាលភាពគ្របដណ្តប់លើគ្រប់អង្គភាពសេដ្ឋកិច្ចទាំងអស់ លើកលែងតែអង្គភាពសេដ្ឋកិច្ចដែលស្ថិតក្នុងវិស័យ (ផ្នែក A) "កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" និង (ផ្នែក I) "សកម្មភាពគ្រួសារ។ ប៉ុន្តែអង្គភាពសេដ្ឋកិច្ចដែលកែច្នៃផលិតផលកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍លទ្ធផលចុងក្រោយ ជាសកម្មភាព "ឧស្សាហកម្មកម្មន្តសាល" (ផ្នែក C) នៃចំណាត់ថ្នាក់វិស័យឧស្សាហកម្មស្តង់ដារអន្តរជាតិ (ឬហៅថា ISIC)។ ផ្អែកតាមនិយមន័យអង្គភាពសេដ្ឋកិច្ច គឺអង្គភាពសេដ្ឋកិច្ច"មានសកម្មភាពអាជីវកម្មគ្មានទីតាំងជាក់លាក់ មិនត្រូវបានរាប់បញ្ចូលក្នុងការធ្វើជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២។ ករណីអង្គភាពទីភ្នាក់ងាររដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា អង្គភាពមូលដ្ឋានយោធា អង្គទូត ក៏មិនត្រូវបានរាប់បញ្ចូលក្នុងការធ្វើជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ នោះទេ។

**អង្គភាព** (Entity)

អង្គភាព គឺជាឈ្មោះទូទៅ ដើម្បីបង្ហាញពីអង្គភាពសេដ្ឋកិច្ចទោល (**អង្គភាពទោល**) ឬ ជាក្រុមអង្គភាពសេដ្ឋកិច្ច ដែលមានការិយាល័យទីស្នាក់ការកណ្តាលនៅព្រះរាជាណាចក្រកម្ពុជា និងមានសាខានៅក្នុង ឬក្រៅប្រទេស (**អង្គភាពច្រើន**)។

**អ្នកតំណាងអង្គភាពសេដ្ឋកិច្ច** (Q3-1)

អ្នកតំណាងអង្គភាពសេដ្ឋកិច្ច គឺមានបុគ្គលម្នាក់ដែលជាអ្នកគ្រប់គ្រងសកម្មភាពការងារអាជីវកម្ម តែមិនមែនជាម្ចាស់អង្គភាពសេដ្ឋកិច្ច។

**សញ្ជាតិម្ចាស់អង្គភាពសេដ្ឋកិច្ច** (Q3-3)

ភាពជាម្ចាស់អង្គភាពសេដ្ឋកិច្ច គឺជាបុគ្គលដែលជាម្ចាស់អង្គភាពអង្គភាពសេដ្ឋកិច្ច។ ក្នុងករណីមានកម្មសិទ្ធិរួមគ្នា សញ្ជាតិនៃម្ចាស់អង្គភាពសេដ្ឋកិច្ច គឺជាសញ្ជាតិរបស់បុគ្គល ដែលមានភាគហ៊ុនច្រើនជាងគេ ហើយនិងក្នុងករណីម្ចាស់ភាគហ៊ុនស្មើគ្នារវាងជនជាតិខ្មែរ និងបរទេស នោះសញ្ជាតិរបស់ម្ចាស់អង្គភាពសេដ្ឋកិច្ចត្រូវបានកំណត់ជាជនជាតិខ្មែរ។

**ភាពជាម្ចាស់/ស្របច្បាប់នៃអង្គភាពសេដ្ឋកិច្ច** (**ស្ថានភាពផ្លូវច្បាប់** Q5)

**១. សហគ្រាសឯកបុគ្គល** (មិនបានចុះបញ្ជី)

សំដៅលើអង្គភាពសេដ្ឋកិច្ចឯកកម្មសិទ្ធិ ក្រៅពី "សហគ្រាសឯកកម្មសិទ្ធិ" ដែលបានបង្ហាញខាងក្រោម។

**២. សហគ្រាសឯកបុគ្គល** (បានចុះបញ្ជី)

សំដៅលើសហគ្រាសឯកកម្មសិទ្ធិដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានីខេត្តដោយស្របតាមច្បាប់ស្តីពីសារពើពន្ធ (ឬច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងការចុះបញ្ជី)។

**៣. ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**

សំដៅលើអង្គភាពសេដ្ឋកិច្ចដែលដំណើរការក្រោមកិច្ចសន្យារវាងមនុស្សពីរនាក់ ឬច្រើននាក់ ដែលបានដាក់ដើមទុនរួមភាគហ៊ុនគ្នា ឬសកម្មភាពរួមគ្នា ដើម្បីអាជីវកម្មក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រាទី៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

**៤. ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត**

សំដៅលើអង្គភាពសេដ្ឋកិច្ចដែលដំណើរការក្រោមកិច្ចសន្យារវាងដៃគូទូទៅមួយ ឬច្រើនដែលត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រង និងចូលរួមក្នុងភាពជាដៃគូ ក៏ដូចជាដៃគូមានកម្រិតមួយ ឬច្រើន ដែលបានចូលហ៊ុនដើមទុន ដូចមានចែងក្នុងមាត្រា៦៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

**៥. សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត**

ជាទម្រង់នៃក្រុមហ៊ុនបានកំណត់ដែលអនុញ្ញាតឱ្យមានកម្មសិទ្ធិ១០០% នៃភាពជាម្ចាស់ឯកបុគ្គល។

### ៦. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ជាទម្រង់នៃក្រុមហ៊ុនមានកំណត់ដែលបំពេញតាមតម្រូវការជាមូលដ្ឋាន ដូចមានចែងក្នុងមាត្រា៨៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម៖

ក). អង្គភាពសេដ្ឋកិច្ចមានម្ចាស់ភាគហ៊ុនពី២ ទៅ ៣០នាក់។

ខ). អង្គភាពសេដ្ឋកិច្ចមិនអាចផ្តល់ភាគហ៊ុន ឬមូលបត្រផ្សេងទៀតរបស់ខ្លួនដល់សាធារណជនទូទៅឡើយ ប៉ុន្តែអាចផ្តល់ជូនដល់ម្ចាស់ភាគហ៊ុនសមាជិកគ្រួសារ និងអ្នកគ្រប់គ្រង។

### ៧. ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

នេះគឺទម្រង់នៃក្រុមហ៊ុនមានកំណត់ដែលត្រូវបានអនុញ្ញាតឱ្យចេញមូលបត្រជាសាធារណៈដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មដូចមានចែងក្នុងមាត្រា៨៧។

### ៨. ផលប្រយោជន៍ក្នុងសម្ព័ន្ធអាជីវកម្មរួម

ភាពជាដៃគូអាជីវកម្មបង្កើតរចនាសម្ព័ន្ធអាជីវកម្មសម្រាប់ប្រយោជន៍ទៅវិញទៅមក។

### ៩. សហគ្រាសសាធារណៈ

ជាទម្រង់សហគ្រាសអាជីវកម្មដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ អង្គភាពសេដ្ឋកិច្ចទាំងនេះ រួមមានធនាគារជាតិនៃកម្ពុជា អគ្គិសនីកម្ពុជា និងរដ្ឋាករទឹកស្វយ័ត។

### ១០. សហគ្រាសរដ្ឋ

ក្រុមហ៊ុនដែលមានដើមទុនទាំងអស់ ជាកម្មសិទ្ធិរបស់រដ្ឋាភិបាលកម្ពុជា។ វាគឺជាអង្គភាពសេដ្ឋកិច្ចដែលត្រូវបានបង្កើតឡើង ដោយផ្អែកលើអនុក្រឹត្យដោយមានការស្នើសុំរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមក្រសួងនីមួយៗ។ អង្គភាពសេដ្ឋកិច្ចទាំងនោះមានដូចជា សាលារៀនសាធារណៈ មន្ទីរពេទ្យរដ្ឋ មណ្ឌលសុខភាព ក្រុមហ៊ុនបោះពុម្ព និងអង្គភាពសេដ្ឋកិច្ចផ្សេងទៀតដែលគ្រប់គ្រងដោយរដ្ឋាភិបាល។

### ១១. ក្រុមហ៊ុនចំរុះរដ្ឋ

ក្រុមហ៊ុនប្រភេទនេះ មានជាទម្រង់អាជីវកម្មផ្អែកលើភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនឯកជនមួយ ឬច្រើន។ ក្នុងការអនុវត្តជាក់ស្តែង គឺរាជរដ្ឋាភិបាលអាចផ្តល់ដើមទុនខ្លះ រួមមានដូចជា ដី ហេដ្ឋារចនាសម្ព័ន្ធ និងធនធានផ្សេងទៀតខណៈដែលក្រុមហ៊ុនឯកជន អាចផ្តល់ដើមទុនខ្លះ ដូចជា បច្ចេកវិទ្យា និងជំនាញបច្ចេកទេសក្នុងការគ្រប់គ្រង។

### ១២. បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស

ក្រុមហ៊ុនប្រភេទនេះ គឺជាផ្នែកនៃក្រុមហ៊ុនបរទេសនៅក្នុងប្រទេសកម្ពុជា ដែលមានភាគហ៊ុនដើមទុនយ៉ាងតិច ៥១% នៃដើមទុនរបស់ខ្លួន ដែលកាន់កាប់ដោយក្រុមហ៊ុនបរទេស ដែលបានចែងក្នុងមាត្រា២៨៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ លើសពីនេះ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនបរទេស អាចមានទម្រង់ជាសហគ្រាសសហកម្មសិទ្ធិ ឬសហគ្រាសទទួលខុសត្រូវមានកម្រិត ដែលបានចែងក្នុងមាត្រា២៨៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

**១៣. សាខាក្រុមហ៊ុនបរទេស**

សាខាក្រុមហ៊ុនបរទេស ត្រូវបានអនុវត្តសកម្មភាព ដូចជាការិយាល័យតំណាងរបស់ក្រុមហ៊ុន ប៉ុន្តែវាគួរតែមានឈ្មោះក្រុមហ៊ុនសំខាន់របស់វា ដោយបូកនិងពាក្យ "សាខា" ។ ក្រុមហ៊ុនសាខាអាចទិញ-លក់ទំនិញ និងសេវាកម្ម ហើយចូលរួមធ្វើអាជីវកម្មស្ថិតក្នុងវិស័យផ្នែកផលិតកម្ម កម្មមន្តសាល ការកែច្នៃ និងសំណង់ មានលក្ខណៈដូចគ្នាទៅនឹងក្រុមហ៊ុនក្នុងស្រុក លើកលែងតែសកម្មភាពទាំងឡាយណាដែលត្រូវបានហាមឃាត់ចំពោះនីតិបុគ្គល ឬរូបវន្តបុគ្គលដូចមានចែងក្នុងមាត្រា ២៧៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

**១៤. ការិយាល័យតំណាង**

ការិយាល័យតំណាងក្រុមហ៊ុនអាជីវកម្ម ឬការិយាល័យទំនាក់ទំនងអាជីវកម្ម អាចធ្វើសកម្មភាពអាជីវកម្មនៅក្នុងក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖

(១).ការផ្សព្វផ្សាយផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនមេ (២).ប្រមូលព័ត៌មានអាជីវកម្ម និងផ្តល់ឱ្យក្រុមហ៊ុនមេនៅបរទេស (៣).ធ្វើការសិក្សាស្រាវជ្រាវទីផ្សារ (៤).ផ្សាយពាណិជ្ជកម្ម ឬដាក់តាំងផលិតផលនៅក្នុងការិយាល័យតំណាងរបស់ពួកគេ ឬកន្លែងផ្សេងទៀតនៅក្នុងប្រទេស។

**១៥. សហករណ៍**

សហករណ៍ គឺជាអង្គភាពអាជីវកម្មដែលមិនស្វែងរកប្រាក់ចំណេញដែលជាកម្មសិទ្ធិរបស់ និងដំណើរការដោយបុគ្គលមួយក្រុមសម្រាប់ផលប្រយោជន៍ទៅវិញទៅមករបស់ពួកគេ។ វាក៏ត្រូវបានកំណត់និយមន័យថាជាអាជីវកម្មដែលជាកម្មសិទ្ធិរបស់ និងគ្រប់គ្រងដោយមនុស្សដែលប្រើប្រាស់សេវាកម្ម ឬធ្វើការ ដើម្បីលើកកម្ពស់សហករណ៍ ដើម្បីស្វែងរកកិច្ចសហការ ឬ ស្រាវជ្រាវព័ត៌មានអំពីទីផ្សារបច្ចុប្បន្ន។

**១៦. អង្គការមិនមែនរដ្ឋាភិបាល (NGO)**

អង្គការមិនមែនរដ្ឋាភិបាលរាប់បញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និងបរទេសទាំងអស់ ដែលផ្តល់ទំនិញនិងសេវាកម្ម ដោយមិនគិតថ្លៃ ឬលក់ក្នុងតម្លៃថ្លៃដើម និងមិនត្រូវបានគ្រប់គ្រង ឬផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាល។ ដោយរួមបញ្ចូលទាំងសហជីព សមាគមវិជ្ជាជីវៈ គណបក្សនយោបាយ អង្គការសប្បុរសធម៌ វត្ត/វត្តអារាម/ដូនជី និងស្ថាប័នសាសនាផ្សេងទៀត និងអង្គការជំនួយដែលផ្តល់ហិរញ្ញប្បទានដោយការផ្ទេរប្រាក់ដោយស្ម័គ្រចិត្ត។

**១៧. អង្គភាពផ្សេងៗទៀត**

**អង្គភាពទោល ការិយាល័យកណ្តាល ឬសាខា (Q6)**

**(១). អង្គភាពទោល**

សំដៅលើអង្គភាពសេដ្ឋកិច្ចតែមួយមិនមានការិយាល័យទីស្នាក់ការកណ្តាល ឬសាខាស្ថិតនៅក្រោមការគ្រប់គ្រងតែមួយនៅកន្លែងផ្សេងគ្នា។

**(២). ការិយាល័យកណ្តាល**

សំដៅលើអង្គភាពសេដ្ឋកិច្ចដែលគ្រប់គ្រងការិយាល័យសាខាទាំងអស់ ស្ថិតនៅក្រោមការគ្រប់គ្រងតែមួយនៅកន្លែងផ្សេងគ្នា។

**(៣). សាខា**

សំដៅលើអង្គភាពសេដ្ឋកិច្ចក្រោមការត្រួតពិនិត្យរបស់ការិយាល័យទីស្នាក់ការកណ្តាលដែលមានទីតាំងនៅកន្លែងផ្សេងគ្នា។

**ការកាន់កាប់កន្លែងអាជីវកម្ម** (Q7-1)

ស្របតាមស្ថានភាពដែលអង្គភាពសេដ្ឋកិច្ចមានទីតាំងផ្ទាល់ខ្លួន ជួលពីគេ ឬប្រើប្រាស់កន្លែងអាជីវកម្មដោយមានការយល់ព្រមពីអាជ្ញាធរឬស្ថាប័នផ្សេងៗ។ល។

**ប្រភេទកន្លែងអាជីវកម្ម** (Q7-2)

**១. អាជីវកម្មតាមដងផ្លូវ**

គឺជាអង្គភាពសេដ្ឋកិច្ចមានលក្ខណៈដូចជា តូប ស្តង់ ជាដើម ដែលដំណើរការអាជីវកម្មនៅទីតាំងជាក់លាក់មួយលើចិញ្ចើមផ្លូវ ឬតាមដងផ្លូវ ឬនៅជុំវិញ ប៉ុន្តែស្ថិតនៅខាងក្រៅផ្សារ។

**២. អាជីវកម្មនៅផ្ទះ**

គឺជាអង្គភាពសេដ្ឋកិច្ចដែលដំណើរការអាជីវកម្មនៅក្នុងផ្នែកមួយនៃលំនៅដ្ឋានដែលម្ចាស់ស្នាក់នៅពិតប្រាកដ។

**៣. អាជីវកម្មនៅក្នុងអគារផ្ទះល្វែង**

គឺជាអង្គភាពសេដ្ឋកិច្ចដែលដំណើរការអាជីវកម្មនៅក្នុងផ្នែកមួយនៃអគារផ្ទះល្វែង ប៉ុន្តែស្ថិតនៅកន្លែងអាជីវកម្ម និងលំនៅដ្ឋានរបស់ម្ចាស់ គឺដាច់ដោយឡែកពីគ្នា។

**៤. អាជីវកម្មនៅក្នុងផ្សារប្រពៃណី**

គឺជាអង្គភាពសេដ្ឋកិច្ចដែលដំណើរការធ្វើអាជីវកម្មស្ថិតនៅផ្នែកជ្រុងមួយ ឬកន្លែងមួយនៅក្នុងផ្សារ ដោយមិនគិតពីការអនុញ្ញាតយល់ព្រម ឬអាជ្ញាប័ណ្ណពីអ្នកគ្រប់គ្រងផ្សារទេ។

**៥. អាជីវកម្មនៅក្នុងផ្សារទំនើប**

គឺជាអង្គភាពអាជីវកម្មមួយដែលដំណើរការធ្វើអាជីវកម្មប្រកបមុខរបរស្ថិតនៅក្នុងផ្សារទំនើបនៃអគារខ្ពស់ដែលមានគ្រឹះស្ថានជាច្រើនកំពុងដំណើរការប្រកបមុខរបរអាជីវកម្ម។

**៦. អង្គភាពអាជីវកម្មដែលកំពុងកាន់កាប់ផ្តាច់មុខក្នុងប្លុកមួយ ឬអគារដាច់ដោយឡែក**

គឺជាអាជីវកម្មដែលមានលក្ខណៈដូចជារោងចក្រ ធនាគារ សាលារៀន វត្តអារាម/វិហារសាសនា មន្ទីរពេទ្យជាដើម កាន់កាប់ប្លុក ឬអគារដាច់ដោយឡែកតែឯង។

### ៧. អង្គភាពផ្សេងទៀត

អង្គភាពទាំងនេះ មានលក្ខណៈដូចជា ហាង ភោជនីយដ្ឋាន កន្លែងម៉ាស្សា ជាដើម។ល។ ដែលស្ថិតក្រោមការគ្រប់គ្រងដាច់ដោយឡែកនៅក្នុងបរិវេណ ឬអគារនៃសណ្ឋាគារ រោងចក្រ ឬសាកលវិទ្យាល័យ។

**ទំហំនៃទីកន្លែងអាជីវកម្ម** (Q7-3): ករណីនេះអាចត្រូវបានពន្យល់បញ្ជាក់ផ្ទាល់បន្ថែមដោយមន្ត្រីជំនាញ

**ម៉ោងធ្វើអាជីវកម្ម** (Q8-1, 2)

សំដៅលើម៉ោងដែលអង្គភាពសេដ្ឋកិច្ចបានបើកដំណើរការ និងបិទធ្វើអាជីវកម្មជាប្រចាំថ្ងៃ។ ប្រភេទនៃម៉ោងធ្វើអាជីវកម្មមានពីរប្រភេទ គឺពេលព្រឹកចាប់ពីម៉ោង ៧ ព្រឹក ដល់ ម៉ោង១២ថ្ងៃត្រង់ និងចាប់ពីម៉ោង១២ថ្ងៃត្រង់ ទៅដល់ម៉ោង ១២យប់។

**ចំនួនអ្នកចូលរួមការងារ** (Q10)

អ្នកចូលរួមការងារនៅក្នុងអង្គភាពសេដ្ឋកិច្ច សម្រាប់កំលុងពេលមួយសប្តាហ៍មុនថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។ ប្រសិនបើមានការផ្លាស់ប្តូរចំនួនអ្នកចូលរួមការងារ គឺត្រូវបានគិតជាមធ្យមរៀងរាល់ថ្ងៃ។ ការរាប់បញ្ចូលអ្នកចូលរួមការងារទាំងអស់ ដែលត្រូវបានជួលដោយអង្គភាពសេដ្ឋកិច្ច ហើយទទួលបានប្រាក់ខែ ឬប្រាក់ឈ្នួល ទោះបីជាត្រូវបានបញ្ជូនទៅអង្គភាពសេដ្ឋកិច្ចផ្សេងទៀតក៏ដោយ។ លើសពីនេះ មិនត្រូវរាប់បញ្ចូលអ្នកដែលធ្វើការនៅអង្គភាពសេដ្ឋកិច្ចផ្សេងទៀតមកធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ចនេះទេ។ ក្នុងករណីនៅការិយាល័យទីស្នាក់ការកណ្តាល មិនត្រូវបានរាប់បញ្ចូលអ្នកចូលរួមការងារនៅសាខានៃអង្គភាពសេដ្ឋកិច្ចនោះទេ។ ម្ចាស់អាជីវកម្ម ត្រូវបានរាប់ជាអ្នកចូលរួមការងារ ប៉ុន្តែប្រធាន ឬនាយកប្រតិបត្តិដែលស្ថិតក្នុងតួនាទីផ្តល់ការងារឱ្យដល់កម្មករនិយោជិត ក៏មិនត្រូវបានរាប់បញ្ចូលក្នុងជំរឿនសេដ្ឋកិច្ចទេ។

(១). **ម្ចាស់អាជីវកម្មដែលធ្វើការឱ្យអង្គភាពសេដ្ឋកិច្ចខ្លួនឯង** (Q10-A1)

ម្ចាស់អាជីវកម្ម ឬអ្នកលក់ និងប្រធាន ឬនាយកដែលជាអ្នកគ្រប់គ្រង និងជាម្ចាស់អង្គភាពសេដ្ឋកិច្ច។

(២). **អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល** (Q10-A2)

សំដៅលើបុគ្គល ដែលជាសមាជិកគ្រួសាររបស់ម្ចាស់អង្គភាពសេដ្ឋកិច្ច និងធ្វើការងារឱ្យអង្គភាពសេដ្ឋកិច្ចក្រោមកិច្ចសន្យាមិនយកប្រាក់ឈ្នួល ឬប្រាក់កំរៃ។

(៣). **នាយកធ្វើការដែលទទួលបានប្រាក់ឈ្នួល** (Q10-A3)

សំដៅលើបុគ្គលដែលជាសមាជិកគ្រួសារជួយអាជីវកម្មក្រោមកិច្ចសន្យាទទួលយកប្រាក់ឈ្នួល។

(៤). **បុគ្គលិកនិយោជិតកម្មករធ្វើការជាប្រចាំ** (Q10-A4)

សំដៅអ្នកដែលមានការងារធ្វើជាប្រចាំបន្ត ដែលមានរយៈពេលលើសពីមួយខែ។

(៥). **កម្មករ/បុគ្គលផ្សេងទៀត ក្រៅពីបុគ្គលិកធ្វើការជាប្រចាំ** (Q10-A5):

សំដៅលើបុគ្គលដែលធ្វើការងារមិនជាប្រចាំ ឬ មិនទៀងទាត់ ឬ មិនមានកិច្ចសន្យាការងារជាអចិន្ត្រៃយ៍។

(៦). **បុគ្គលដែលចូលរួមការងារដោយស្ម័គ្រចិត្ត** (Q10-B)

សំដៅលើបុគ្គលដែលចូលរួមដោយស្ម័គ្រចិត្តនៅក្នុងអង្គភាពសេដ្ឋកិច្ច ដោយគ្មានកិច្ចសន្យាការងារ និងគ្មានប្រាក់រង្វាន់សម្រាប់ការងារ ដូចជាប្រាក់ឈ្នួល ឬប្រាក់ខែ ដែលរួមមានព្រះសង្ឃ បុព្វជិត ដូនជី បងប្អូនស្រី ជាដើម។ ដែលពួកគេអាចនឹងទទួលបានរង្វាន់ជាវត្ថុ(របស់) ឬ ប្រាក់រង្វាន់។

**ប្រភេទសកម្មភាពអាជីវកម្មចម្បង (Q11)**

ក្នុងករណីអង្គភាពមានប្រភេទសកម្មភាពជាច្រើន គឺត្រូវបានយកសកម្មភាពអាជីវកម្មចម្បងដែលត្រូវគិតពិចារណាលើតម្លៃបន្ថែម ឬធនធានមនុស្សដែលបានប្រើប្រាស់។ ក្នុងករណីការិយាល័យទីស្នាក់ការកណ្តាល មានសកម្មភាពសាខារបស់ខ្លួន គឺមិនត្រូវបានយកមកពិចារណានោះទេ។

**ចំនួនការិយាល័យសាខា (Q12)**

ចំនួនការិយាល័យសាខាសរុបដែលមានការិយាល័យទីស្នាក់ការកណ្តាល សម្រាប់ការគ្រប់គ្រង ឃ្លាំង ឬអន្តេវាសិកដ្ឋានដែលបុគ្គលិករបស់អង្គភាពសេដ្ឋកិច្ចធ្វើការនោះ គឺត្រូវបានរាប់បញ្ចូល។

**ចំនួនបុគ្គលិកនិយោជិតជម្មតា (Q14)**

ចំនួនសរុបនៃនិយោជិតធម្មតាដែលបានចូលរួមទាំងនៅការិយាល័យទីស្នាក់ការកណ្តាល និងសាខា នៅដំណាច់ខែធ្នូ ឆ្នាំ២០២១។

**ប្រភេទនៃសកម្មភាពអាជីវកម្មសំខាន់របស់អង្គភាពអាជីវកម្ម (Q14-1)**

ក្នុងករណីអង្គភាពសេដ្ឋកិច្ចមានសកម្មភាពច្រើន ត្រូវបានយកសកម្មភាពចម្បងនៅក្នុងផ្នែកតម្លៃបន្ថែម ឬមានជាតុចូលដែលសំខាន់បំផុត។

**ប្រភេទនៃសកម្មភាពអាជីវកម្មចម្បងបន្ទាប់បន្សំទីពីរ (Q14-2)**

សកម្មភាពអាជីវកម្មចម្បងទីពីរ គឺត្រូវបានកំណត់លើតម្លៃបន្ថែមដែលមានភាគចំណែកធំបំផុតទីពីរ ឬកម្លាំងអ្នកចូលរួមការងារធំបំផុតទីពីរដែលបានប្រើប្រាស់នៅក្នុងដំណើរការអាជីវកម្មនៃអង្គភាពសេដ្ឋកិច្ច។

**ចំនួនថ្ងៃធ្វើការក្នុងខែកុម្ភៈ ឆ្នាំ២០២២ (Q16-3)**

ព័ត៌មានត្រូវបានទទួលពីអង្គភាពសេដ្ឋកិច្ចទោល និងការិយាល័យទីស្នាក់ការកណ្តាល នៃអង្គភាពសេដ្ឋកិច្ចដែលមានអង្គភាពច្រើន។

**ចំណូលពីការលក់ ការចំណាយ និងប្រាក់ចំណេញ និងខាត ប្រចាំឆ្នាំ (Q16 និង 21)**

**ចំណូលពីការលក់ប្រចាំឆ្នាំ (Q16 និង Q 21)**

**(១). ករណីអង្គភាពសេដ្ឋកិច្ចដែលមានតារាងតុល្យការ ឬរបាយការណ៍ចំណូល**

ទឹកប្រាក់សរុបនៅឆ្នាំ២០២១ និង ផលបូកនៃប្រាក់ចំណូលប្រតិបត្តិការ (Q21-1) និងប្រាក់ចំណូលផ្សេងទៀត (Q21-4) ដែលមាននៅក្នុងតារាងសំណួរអង្គភាពសេដ្ឋកិច្ចនៃជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២។

**(២). ករណីអង្គភាពសេដ្ឋកិច្ចដែលមិនមានតារាងតុល្យការ ឬរបាយការណ៍ចំណូល**

ចំនួនទឹកប្រាក់នេះត្រូវបានប៉ាន់ប្រមាណអំពីតួលេខប្រចាំថ្ងៃ ឬប្រចាំខែក្នុងខែកុម្ភៈ ឆ្នាំ២០២២។ មានន័យថាមួយខែមុនខែនៃការធ្វើជំរឿន ឬខែចុងក្រោយបំផុត។ វិធីសាស្ត្រប៉ាន់ស្មាន គឺយកតួលេខចំណាយប្រចាំថ្ងៃគុណនឹង៣៦៥ថ្ងៃ ឬតួលេខចំណាយប្រចាំខែគុណនឹង១២ខែ ហើយនិងវាអាស្រ័យលើការឆ្លើយតបទៅនឹងអថេរនៃតារាងសំណួរជំរឿនអង្គភាពសេដ្ឋកិច្ច។

**ការចំណាយប្រចាំឆ្នាំ (Q16 និង Q21)**

**(១). ករណីអង្គភាពសេដ្ឋកិច្ចដែលមានតារាងតុល្យការ ឬរបាយការណ៍ចំណូល**

ទឹកប្រាក់សរុបនៅឆ្នាំ២០២១ និងសរុបថ្លៃដើមប្រតិបត្តិការ (Q21-2) ចំណាយប្រតិបត្តិការ (Q21-5) ចំណាយការប្រាក់បង់ឱ្យនិវាសនជន (បុគ្គលដែលរស់នៅក្នុងកន្លែង ឬទីតាំងជាក់លាក់ណាមួយ ជាធម្មតាសម្រាប់រយៈពេលបន្ថែម (Q21-6)) ចំណាយការប្រាក់បង់ឱ្យអនិវាសនជន (បុគ្គលដែលមិនរស់នៅទីកន្លែង ឬទីតាំងជាក់លាក់ណាមួយជាអចិន្ត្រៃយ៍ ឬរយៈពេលវែង (Q21-7) ប្រាក់ចំណេញ/ខាតមុនពេលបង់ពន្ធ (Q21-9) ដែលមាននៅក្នុងកម្រងតារាងសំណួរអង្គភាពសេដ្ឋកិច្ច។

**(២).ករណីអង្គភាពសេដ្ឋកិច្ចដែលមិនមានតារាងតុល្យការ និងរបាយការណ៍លទ្ធផល(ចំណូល-ចំណាយ)**

ចំនួនទឹកប្រាក់នេះ ត្រូវបានប៉ាន់ប្រមាណអំពីតួលេខប្រចាំថ្ងៃ ឬប្រចាំខែក្នុងខែកុម្ភៈ ឆ្នាំ២០២២។ មានន័យថាមួយខែមុនខែនៃការធ្វើជំរឿន ឬខែចុងក្រោយបំផុត។ វិធីសាស្ត្រប៉ាន់ស្មាន គឺយកតួលេខចំណាយប្រចាំថ្ងៃ គុណនឹង៣៦៥ថ្ងៃ ឬតួលេខចំណាយប្រចាំខែគុណនឹង១២ខែ អាស្រ័យលើការឆ្លើយតបទៅនឹងកម្រងសំណួរជំរឿនសេដ្ឋកិច្ច។

**ប្រាក់ខែ និងប្រាក់ឈ្នួលបុគ្គលិក និយោជិតកម្មករ ប្រចាំឆ្នាំ (Q16 និង Q21)**

**(១). ករណីអង្គភាពសេដ្ឋកិច្ច ដែលមានតារាងតុល្យការ ឬរបាយការណ៍ចំណូល ចំណាយ**

ចំនួនទឹកប្រាក់សរុបសម្រាប់ឆ្នាំ២០២១ និងឆ្លើយតបទៅសំណួរ (Q21-5-1) (ចំណាយប្រាក់ខែ និងប្រាក់ឈ្នួល) ក្នុងតារាងសំណួរអង្គភាពសេដ្ឋកិច្ច។ ទោះបីយ៉ាងណាសំណួរ (Q21-5-1) មិនបានរាប់បញ្ចូលប្រាក់ខែ និងប្រាក់ឈ្នួលសម្រាប់អ្នកគ្រប់គ្រង និងនិយោជិតកម្មករនៅក្នុងផ្នែកផលិតកម្ម។ ប្រាក់ខែ និងប្រាក់ឈ្នួលទាំងនោះ ត្រូវបានបញ្ចូលក្នុងសំណួរអង្គភាពសេដ្ឋកិច្ច (Q21-2-1)។

**(២). ករណីអង្គភាពសេដ្ឋកិច្ច ដែលមិនមានតារាងតុល្យការ និងរបាយការណ៍ចំណូល ចំណាយ**

ផ្អែកតាមការវិភាគព័ត៌មានខាងលើ ចំពោះករណី"ការចំណាយប្រចាំឆ្នាំ" ត្រូវបានអនុវត្តប្រមូលទិន្នន័យមាននៅក្នុងតារាងសំណួរអង្គភាពសេដ្ឋកិច្ចក្នុងផ្នែកចំណាយប្រតិបត្តិការ(Q16-2) ត្រូវបានជំនួសដោយសំណួរចំណាយលើប្រាក់ខែ និងប្រាក់ឈ្នួលបុគ្គលិក (Q16-2-1)។

**ប្រាក់ចំណេញ និងខាត ប្រចាំឆ្នាំ របស់អង្គភាពសេដ្ឋកិច្ច**

ប្រាក់ចំណេញ និងខាតប្រចាំឆ្នាំ = ការលក់ប្រចាំឆ្នាំ - ការចំណាយប្រចាំឆ្នាំ

**អនុបាតនៃតម្លៃពលកម្មធៀបទៅនឹងការលក់**

អនុបាតនៃចំណាយពលកម្ម = ចំណាយប្រាក់ខែ និងប្រាក់ឈ្នួលប្រចាំឆ្នាំ / ការលក់ប្រចាំឆ្នាំ × 100

**(១) ប្រាក់ចំណេញដុល**

ប្រាក់ចំណេញដុល គឺជាភាពខុសគ្នារវាងចំណូលប្រតិបត្តិការ (Q21-1) និងថ្លៃដើមប្រតិបត្តិការ (Q21-2)។

**ទ្រព្យសកម្មរយៈពេលវែង** (Fixed Assets "Q17-1")

សរុបទ្រព្យសកម្មរយៈពេលវែងរបស់អង្គភាពសេដ្ឋកិច្ចដែលមាននៅដំណាច់ខែធ្នូ ឆ្នាំ២០២១ រួមមានៈ ១.ដីធ្លីរបស់សហគ្រាស ២.ការរៀបចំតុបតែងលម្អដីធ្លីរបស់សហគ្រាស ៣.សំណង់អគាររបស់សហគ្រាស ៤.សំណង់អគារលើដីធ្លីក្រោមភតិសន្យា ៥.ទ្រព្យសកម្មរយៈពេលវែងកំពុងដំណើរការ ៦.រោងចក្រ (ក្រៅពីអគារ) និងបរិក្ខារ ៧.កេរ្តិ៍ឈ្មោះ/មូលនិធិពាណិជ្ជកម្ម ៨. ចំណាយបង្កើតសហគ្រាសដំបូង ៩.ទ្រព្យសកម្មក្រោមភតិសន្យា និងបុព្វលាភនៃការប្រើប្រាស់ ១០.វិនិយោគក្នុងសហគ្រាសដទៃ ១១. ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ។

**ទ្រព្យសកម្មរយៈពេលខ្លី** (Q17-2)

ទ្រព្យសកម្មរយៈពេលខ្លីនៅដំណាច់ខែធ្នូ ឆ្នាំ២០២១ រួមមាន ១ចំនួនសន្និធិវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ ២.ស្តុកទំនិញសម្រាប់លក់ ៣.ស្តុកផលិតផលសម្រេច ៤.ផលិតផលកំពុងដំណើរការ ៥.គណនីត្រូវទទួល/អតិថិជន ៦.គណនីត្រូវទទួលផ្សេងៗ ៧.ចំណាយបានកត់ត្រាមុន ៨.សាច់ប្រាក់នៅក្នុងបេឡា និងធនាគារ ៩.ឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូល ១០.ឥណទានពន្ធអាករលើតម្លៃបន្ថែម ១១.ឥណទានពន្ធ-អាករដទៃទៀត ១២.ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ ១៣. លម្អៀងពីការប្តូរប្រាក់នៃទ្រព្យសកម្ម។

**មូលនិធិ** (Q18)

ចំនួនសរុបមូលនិធិដែលមាននៅដំណាច់ខែធ្នូ ឆ្នាំ២០២១៖ ១.មូលធន/មូលធនភាគហ៊ុន ២.តម្លៃលើសនៃការលក់ប័ណ្ណភាគហ៊ុន ៣.មូលធនបម្រុងតាមច្បាប់ ៤.លម្អៀងលើសនៃការវាយតម្លៃឡើងវិញនូវទ្រព្យសកម្ម ៥.មូលធនបម្រុងផ្សេងៗ ៦.លទ្ធផលចំណេញ /(ខាត)យោងពីមុន និងក្នុងឆ្នាំការិយបរិច្ឆេទយោង។

**បំណុលរយៈពេលវែង** (Q19)

សរុបបំណុលរយៈពេលវែងរបស់អង្គភាពសេដ្ឋកិច្ចដែលមាននៅដំណាច់ខែធ្នូ ឆ្នាំ២០២១ ដូចជា៖ ១.បំណុលភាគីជាប់ទាក់ទិន ២.បំណុលធនាគារ និងបំណុលភាគីមិនជាប់ទាក់ទិនផ្សេងៗ ៣.សំវិធានធន និង ៤.បំណុលរយៈពេលវែងផ្សេងៗ

**បំណុលរយៈពេលខ្លី** (Q20)

សរុបបំណុលរយៈពេលខ្លីរបស់អង្គភាពសេដ្ឋកិច្ចដែលមាននៅដំណាច់ខែធ្នូ ឆ្នាំ២០២១ រួមមាន៖ ១.សាច់ប្រាក់ដកពីធនាគារលើសប្រាក់បញ្ញើ (ឥណទានវិបារូប៍) ២.ចំណែកចរន្តនៃបំណុលមានការប្រាក់ ៣.គណនីត្រូវសងបុគ្គលជាប់ទាក់ទិន (ភាគីសម្ព័ន្ធញាតិ) ៤.គណនីត្រូវសងផ្សេងៗ ៥.ចំណូលកត់មុន ៦.គណនីចំណាយបង្ករ និងបំណុលរយៈពេលខ្លីផ្សេងៗ ៧.សំវិធានធន ៨.ពន្ធលើប្រាក់ចំណូលត្រូវបង់ និងពន្ធ-អាករផ្សេងៗត្រូវបង់ ៩.លម្អៀងពីការប្តូរប្រាក់នៃទ្រព្យអកម្ម។

**របាយការណ៍លទ្ធផលនៅក្នុងឆ្នាំ២០២១ ដែលកត់ត្រាអំពីចំណូល និងចំណាយតាម " ប្រព័ន្ធគណនេយ្យបង្គរ (Q21) និងចំណូលប្រតិបត្តិការ (Q21-1)**

ចំណូលប្រតិបត្តិការរបស់អង្គភាពសេដ្ឋកិច្ច រួមមាន៖ ១.ចំណូលពីការលក់ផលិតផលដែលបានផលិតក្នុងវិស័យផ្នែកកម្មមន្តសាល ២.ការលក់ទំនិញ និង ៣.ការផ្គត់ផ្គង់សេវា។

**ថ្លៃដើមប្រតិបត្តិការ (Q21-2)**

១.ថ្លៃដើមផលិតផលបានលក់របស់សហគ្រាសផលិតកម្ម ២.ថ្លៃដើមទំនិញបានលក់របស់សហគ្រាសក្រៅពីផលិតកម្ម និង៣.ថ្លៃដើមសេវាបានផ្គត់ផ្គង់។

**ប្រាក់ចំណូលផ្សេងទៀត (Q21-3)**

ប្រាក់ចំណូលផ្សេងៗរួមមាន៖ ចំណូលពីការជួលបានទទួល ឬត្រូវទទួល ចំណូលពីសួយសារបានទទួល ឬត្រូវទទួល និងចំណូលបន្ទាប់បន្សំដទៃទៀត ដូចជា៖ ឧបត្ថម្ភកធន ចំណូលពីភាគលាភបានទទួល ឬត្រូវទទួល ចំណូលពីការប្រាក់បានទទួល ឬត្រូវទទួល ផលចំណេញ/តម្លៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែង ផលចំណេញពីការលក់មូលបត្រ/សញ្ញាប័ណ្ណ ភាគចំណេញពីប្រតិបត្តិការរួមគ្នា ផលចំណេញពីការប្តូរប្រាក់សម្រេចបាន ផលចំណេញពីការប្តូរប្រាក់មិនទាន់សម្រេចបាន និងចំណូលដទៃទៀត។

**ចំណាយប្រតិបត្តិការ (Q21-4):**

ចំណាយប្រតិបត្តិការរបស់អង្គភាពសេដ្ឋកិច្ច រួមមាន៖ ១).ចំណាយប្រាក់បៀវត្ស និងប្រាក់ឈ្នួល ២).ចំណាយប្រេង ឧស្ម័ន អគ្គិសនី និងទឹក ៣).ចំណាយធ្វើដំណើរ និងចំណាយស្នាក់នៅ ៤).ចំណាយដឹកជញ្ជូន ៥).ចំណាយលើការជួល ៦).ចំណាយលើការថែទាំ និងជួសជុល ៨).ចំណាយលើការកម្សាន្តសប្បាយ ៨).ចំណាយកម្រៃជើងសារផ្សាយពាណិជ្ជកម្ម និងចំណាយការលក់ ៩).ចំណាយបង់ពន្ធ និងអាករផ្សេងៗ ១០).ចំណាយលើអំណោយ ១១). ចំណាយសេវាគ្រប់គ្រង ពិគ្រោះយោបល់ បច្ចេកទេស និងសេវាប្រហាក់ប្រហែល ១២).ចំណាយលើសួយសារ ១៣). ចំណាយលើបំណុលទារមិនបាន ១៤).ចំណាយរំលស់ ១៥).ការកើនឡើង/ថយចុះ នូវសំវិធានធន ១៦).ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង ១៧).ខាតពីការប្តូរប្រាក់សម្រេចបាន ១៨).ខាតពីការប្តូរប្រាក់មិនទាន់សម្រេចបាន ១៩).ចំណាយផ្សេងៗ។ ចំណាយដែលកើតឡើងនៅក្នុងផ្នែកផលិតកម្ម មិនត្រូវបានរាប់បញ្ចូលក្នុងចំណាយប្រតិប្តិការដែលបានរាយខាងលើទេ ប្រសិនបើមានណាមួយត្រូវបញ្ចូលនៅក្នុងសំណួរ (Q21-2-1)។

**ចំណាត់ថ្នាក់នៃអង្គភាពសេដ្ឋកិច្ចតាមវិស័យសកម្មភាពសេដ្ឋកិច្ច (Q11)**

វិស័យសំខាន់នៃវិស័យឧស្សាហកម្ម ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកតាមប្រភេទនៃសកម្មភាពអាជីវកម្មចម្បងរបស់អង្គភាពសេដ្ឋកិច្ចដែលបានសម្ភាសន៍ម្ចាស់អង្គភាពសេដ្ឋកិច្ច ឬអ្នកតំណាង។ ការកំណត់បែងចែកអង្គភាពសេដ្ឋកិច្ចតាមវិស័យសកម្មភាពសេដ្ឋកិច្ច គឺត្រូវបានប្រើប្រាស់ចំណាត់ថ្នាក់វិស័យឧស្សាហកម្មស្តង់ដារអន្តរជាតិរបស់អង្គការសហប្រជាជាតិ ឬហៅថា UN, ISIC Rev.4 (United Nation, International Standard Industrial Classification Revision 4)។

# របាយការណ៍វិភាគសង្ខេបអំពីលទ្ធផលចុងក្រោយនៃជំរឿនសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២

ជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២ ត្រូវបានធ្វើដោយកំណត់យកថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ជាកាលបរិច្ឆេទយោង។ ការធ្វើជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២ គ្របដណ្តប់លើអង្គភាពសេដ្ឋកិច្ចមានទីតាំងជាក់លាក់អចិន្ត្រៃយ៍ទាំងអស់ ដែលស្ថិតក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ លទ្ធផលចុងក្រោយនៃការធ្វើជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ នឹងត្រូវផ្សព្វផ្សាយនៅខែសីហា ឆ្នាំ២០២៣ បន្ទាប់ពីការប្រព្រឹត្តកម្មទិន្នន័យ និងវិភាគទិន្នន័យអស់រយៈពេលជាងមួយឆ្នាំ ដូចមានខ្លឹមសង្ខេបខាងក្រោម៖

## ១. សរុបអង្គភាពសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា មានចំនួន ៧៥៣.៦៧០ អង្គភាពសេដ្ឋកិច្ច

នៅប្រទេសកម្ពុជាមានអង្គភាពសេដ្ឋកិច្ចចំនួន ៧៥៣.៦៧០សហគ្រាស គិតត្រឹមថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ជាលទ្ធផលចុងក្រោយនៃជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២។ ចំនួនអ្នកចូលរួមការងារនៅក្នុងអង្គភាពសេដ្ឋកិច្ចមានចំនួន ២.៩៨០.៥៦៩នាក់ ក្នុងនោះ បុរសមាន ១.១៣៩.២០៧ នាក់ ស្មើនឹង ៣៨,២% និងស្ត្រីមាន ១.៨៤១.៣៦២នាក់ ស្មើនឹង ៦១,៨% (មើលតារាង១.១ និង តារាង១១.១.១)។ ប្រសិនបើករណីមិនរាប់បញ្ចូលអង្គភាពសេដ្ឋកិច្ចតាមចិញ្ចើមផ្លូវទេនោះ ចំនួនអង្គភាពសេដ្ឋកិច្ចទាំងអស់មានចំនួន ៦៧៦.៥៩៧ សហគ្រាស និងមានអ្នកចូលរួមការងារសរុបនៅក្នុងអង្គភាពសេដ្ឋកិច្ចចំនួន ២.៨៦៤.២៥៦ នាក់ (មើលតារាង១.៧.១ និងតារាង១១.៧.១)។

បើប្រៀបធៀបលទ្ធផលចុងក្រោយនៃជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ ទៅនឹងលទ្ធផលនៃជំរឿនសេដ្ឋកិច្ចនៅឆ្នាំ២០១១ បានឱ្យដឹងថាចំនួនអង្គភាពសេដ្ឋកិច្ចនៅឆ្នាំ២០២២ បានកើនឡើងប្រមាណ ៤៩% ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំមាន ៣,៧%។ នៅកំលុងពេលដូចគ្នានេះដែរ មានអ្នកចូលរួមការងារបានកើនឡើងដល់ ៧០,៩% ដែលបណ្តាលឱ្យអត្រាកំណើនប្រចាំឆ្នាំមានប្រមាណ ៥% ដែលមានកម្រិតខ្ពស់ជាងអត្រាកំណើនប្រជាជនគួរឱ្យកត់សម្គាល់ ដែលមានប្រមាណ ១,៤% តែប៉ុណ្ណោះ។

ចំនួនអង្គភាពសេដ្ឋកិច្ចភាគច្រើន គឺមានម្ចាស់ជាជនជាតិកម្ពុជា ដែលមានប្រមាណ ៩៩,១% នៃអង្គភាពសេដ្ឋកិច្ចសរុបទាំងអស់នៅប្រទេសកម្ពុជា ឆ្នាំ២០២២ (មើលតារាង ២.២.១ និង តារាង ២.២.៣)។ ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានម្ចាស់ជាជនជាតិកម្ពុជា មានប្រមាណ ៧៤៧.០១០ សហគ្រាស (៩៩,១%) ហើយនិងអង្គភាពសេដ្ឋកិច្ចដែលមានម្ចាស់ជាជនជាតិចិនមាន ២.៦០៨ សហគ្រាស (០,៣%) ម្ចាស់ជាជនជាតិវៀតណាមមាន ១.៥៨១ សហគ្រាស (០,២%) ម្ចាស់ជាជនជាតិអាស៊ីផ្សេងៗទៀតមាន ១.១៩៨ សហគ្រាស (០,២%) និងជនជាតិកូរ៉េខាងត្បូងមាន ៤៣៩ សហគ្រាស (០,១%)។ ចំណែកអង្គភាពសេដ្ឋកិច្ចដែលម្ចាស់បរទេសមានភាគហ៊ុនជាមួយកម្ពុជា គឺមានតិចជាង ១% នៅឆ្នាំ២០២២។ លំនាំគំរូនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច គឺមានលក្ខណៈលំនាំស្រដៀងគ្នាទៅនឹង ករណីស្ថានភាពសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០១១ ដែរ ដែលមានចំនួនអង្គភាពសេដ្ឋកិច្ចមាន ៩៨,៩% នៃអង្គភាពសេដ្ឋកិច្ចទាំងអស់នៅកម្ពុជា។

បើប្រៀបធៀបទៅនឹងលទ្ធផលទិន្នន័យជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១(EC2011) ចំនួនអង្គភាពសេដ្ឋកិច្ចដែលមិនត្រូវបានរាប់បញ្ចូលអង្គភាពសេដ្ឋកិច្ចតាមចិញ្ចើមផ្លូវទេនោះ ចំនួនអង្គភាពសេដ្ឋកិច្ចបានកើនឡើងចំនួន ២១៣.២៣៤

សហគ្រាស ស្មើនឹង ៤៦% នៅខណៈដែលចំនួនអង្គភាពសេដ្ឋកិច្ចតាមចិញ្ចើមផ្លូវ បានកើនឡើងចំនួន ៣៥.៣០២ សហគ្រាស ស្មើនឹង ៨៤% នៃអង្គភាពសេដ្ឋកិច្ចសរុប។

ផ្អែកលើលទ្ធផលនៃជំរឿនសេដ្ឋកិច្ចនេះ បានបង្ហាញថាចំនួនអង្គភាពសេដ្ឋកិច្ចតាមចិញ្ចើមផ្លូវមានអត្រាកំណើនខ្ពស់ជាងអង្គភាពសេដ្ឋកិច្ចផ្សេងទៀតនៅក្នុងចន្លោះរវាងឆ្នាំ២០១១ និង ឆ្នាំ២០២២។

## ២. ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារ១ ឬ២នាក់ មានចំនួនច្រើនជាង ៨០%

ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារ១នាក់ ឬ២នាក់ មានប្រមាណ ៦២១.០២៨ សហគ្រាស ស្មើនឹង ៨២,៤% និងមានទំហំនៃអ្នកចូលរួមការងារ២នាក់ មានប្រមាណ ២៥៣.៨៥៧ សហគ្រាស ស្មើនឹង៣៣,៧%។ ដូចនេះ ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានទំហំនៃអ្នកចូលរួមការងារ១នាក់ ឬ២នាក់ គឺមានចំណែកភាគច្រើនបំផុតនៅក្នុងចំនួនសរុបអង្គភាពសេដ្ឋកិច្ចនៅកម្ពុជា (មើលតារាង១.១)។

ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារពី៥នាក់ ឬច្រើនជាង ដែលជាក្រុមធំបន្ទាប់គឺមានប្រមាណ ៥៣.៧២៤ សហគ្រាស ស្មើនឹង៧,២% នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប។ ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារ១០នាក់ ឬច្រើនជាង មានប្រមាណ ២០.៨២០ សហគ្រាស ស្មើនឹង ២,៨%។ ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារ១០០នាក់ ឬច្រើនជាង មានប្រមាណ ១.៨៧០ ស្មើនឹង ០,២% និងចំនួនអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារ១០០០នាក់ ឬច្រើនជាង មានប្រមាណ ២៩៥ សហគ្រាស តែប៉ុណ្ណោះ។ មានន័យថានៅប្រទេសកម្ពុជា ចំនួនអង្គភាពសេដ្ឋកិច្ចខ្នាតធំ គឺមានអត្រាសមាមាត្រទាបបំផុតនៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប (មើលតារាង១.១)។

សម្រាប់រយៈពេលដូចគ្នា ចំនួនអ្នកចូលរួមការងារសម្រាប់នៅអង្គភាពសេដ្ឋកិច្ចដែលមានទំហំនៃអ្នកចូលរួមការងារចាប់ពី៥នាក់ ឬច្រើនជាង គឺមានអ្នកចូលរួមការងារប្រមាណ ១,៨៤ លាននាក់ ស្មើនឹង ៦១,៩% នៃអ្នកចូលរួមការងារសរុប។ អង្គភាពសេដ្ឋកិច្ចដែលមានទំហំនៃអ្នកចូលរួមការងារ១០នាក់ ឬច្រើនជាង មានអ្នកចូលរួមការងារប្រមាណ ១,៦៣លាន ស្មើនឹង ៥៥,០% និងអង្គភាពសេដ្ឋកិច្ចដែលមានទំហំនៃអ្នកចូលរួមការងារចាប់ពី១០០នាក់ ឬច្រើនជាង មានអ្នកចូលរួមការងារប្រមាណ ១,២១លាននាក់ ស្មើនឹង ៤០,៨% និងអង្គភាពសេដ្ឋកិច្ចដែលមានទំហំនៃអ្នកចូលរួមការងារចាប់ពី១០០០នាក់ ឬច្រើនជាង មានអ្នកចូលរួមការងារប្រមាណ ៦៦៣.៤២៦ នាក់ ស្មើនឹង ២២,៣%។ ដូច្នេះ ទោះបីជាចំនួនអង្គភាពសេដ្ឋកិច្ចធំៗមានចំនួនតិចនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែអង្គភាពសេដ្ឋកិច្ចទាំងនេះនៅតែមានសមាមាត្រអ្នកចូលរួមការងារខ្ពស់បំផុត (មើលតារាង ១១.១.១)។

## ៣. អង្គភាពសេដ្ឋកិច្ចថ្មីមានប្រមាណ ២៤១.៨២១ សហគ្រាស ស្មើនឹង មួយភាគបី(១/៣)នៃអង្គភាពសេដ្ឋកិច្ចសរុប

ចំនួនអង្គភាពសេដ្ឋកិច្ចថ្មីមាន ២៤១.៨២១ សហគ្រាស ដែលបានចាប់ផ្តើមធ្វើអាជីវកម្មនៅចន្លោះរវាងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។ អង្គភាពសេដ្ឋកិច្ចថ្មីៗមានប្រមាណ ៣២,១% នៃអង្គភាពសេដ្ឋកិច្ចសរុប។ អង្គភាពសេដ្ឋកិច្ចថ្មីទាំងនេះ បានកើតមានឡើងនៅក្នុងខែមករា ឆ្នាំ២០២០ ឬនៅក្នុងកំលុងពេលដែលប្រទេសកម្ពុជាបានទទួលរងការរាតត្បាតនៃជំងឺកូវីដ១៩ផងដែរ (មើលតារាង១.៩.១)។

## ៤. អាជីវកម្មតាមចិញ្ចើមផ្លូវ មានអង្គភាពសេដ្ឋកិច្ចចំនួន ៧៧.០៧៣ សហគ្រាស

អង្គភាពសេដ្ឋកិច្ចដែលធ្វើសកម្មភាពអាជីវកម្មតាមចិញ្ចើមផ្លូវ គឺជាអង្គភាពអាជីវកម្មដែលមានលក្ខណៈដូចជាតូប ឬស្តង់ជាដើម ដែលមានទីតាំងអាជីវកម្មដាក់លាក់នៅលើចិញ្ចើមផ្លូវ។ អង្គភាពសេដ្ឋកិច្ចធ្វើអាជីវកម្មតាមចិញ្ចើមផ្លូវមានប្រមាណ ១០,២% នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប។ បន្ថែមលើសពីនេះ អង្គភាពអាជីវកម្មតាមចិញ្ចើមផ្លូវដែលមានតំណាងជាស្ត្រី មានប្រមាណ ៧៥% នៃអាជីវកម្មតាមចិញ្ចើមផ្លូវសរុប។ អង្គភាពអាជីវកម្មតាមចិញ្ចើមផ្លូវដែលមានអ្នកចូលរួមការងារមានទំហំ១នាក់ ឬ២នាក់ មានប្រមាណ ៨៩% នៃអ្នកចូលរួមធ្វើការងារដែលមានម្ចាស់អង្គភាពអាជីវកម្មដែលមានតំណាងជាស្ត្រី (មើលតារាង ១.៧.១)។

## ៥. សហគ្រាសឯកកម្មសិទ្ធិ/រូបវន្តបុគ្គល មានប្រមាណ ៩៦,៥%

អង្គភាពសេដ្ឋកិច្ច គឺជាសហគ្រាសឯកកម្មសិទ្ធិ ឬ រូបវន្តបុគ្គល មានចំនួនប្រមាណ ៧៣៤.៧៣៩ សហគ្រាស ស្មើនឹង ៩៦,៥% នៃអង្គភាពសេដ្ឋកិច្ចសរុបនៅឆ្នាំ២០២២(មើលតារាង១.៤.១)។ លទ្ធផលជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ បានបង្ហាញថានៅប្រទេសកម្ពុជា មានអង្គភាពសេដ្ឋកិច្ចភាគច្រើនបំផុត ត្រូវបានគ្រប់គ្រង និងកាន់កាប់ធ្វើប្រតិបត្តិការអាជីវកម្ម ដោយមនុស្សតែម្នាក់(ឬម្ចាស់ម្នាក់ឯង)។ បន្ថែមលើពីនេះ ចំនួនអ្នកចូលរួមការងារក្នុងអង្គភាពសេដ្ឋកិច្ចប្រភេទនេះ មានចំនួនប្រមាណ ២.៨១៤.៧៧៥ នាក់ ស្មើនឹង ៩៤% នៃអ្នកចូលរួមការងារសរុបនៅក្នុងឆ្នាំ២០២២ (មើលតារាង១១.៤.១)។ ផ្អែកលើទិន្នន័យលទ្ធផលជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ បានបង្ហាញថាអង្គភាពសេដ្ឋកិច្ចប្រភេទនេះ គឺមានចំនួនច្រើនលើសលុបផងដែរប្រមាណ ៩៦,០% នៃអង្គភាពសេដ្ឋកិច្ចសរុបនៅឆ្នាំ២០១១។

## ៦. ម្ចាស់អង្គភាពសេដ្ឋកិច្ច " មានកម្មសិទ្ធិកាន់កាប់ទីតាំងអាជីវកម្ម" មានប្រមាណជិត ៧៣%

បើពិនិត្យលើកម្មសិទ្ធិកាន់កាប់ទីកន្លែងអាជីវកម្ម បានបង្ហាញថាអង្គភាពសេដ្ឋកិច្ច មានចំនួនប្រមាណ ៧២,៧% ដែលមានកម្មសិទ្ធិកាន់កាប់ទីកន្លែងអាជីវកម្ម។ មានន័យថា ចំនួនអង្គភាពសេដ្ឋកិច្ចដែលមានកម្មសិទ្ធិកាន់កាប់ទីកន្លែងអាជីវកម្ម គឺមានកម្រិតចំនួនខ្ពស់នៅក្នុងប្រទេសកម្ពុជា(មើលតារាង១.៦)។ ផ្អែកតាមលទ្ធផលជំរឿនសេដ្ឋកិច្ចក៏បានបង្ហាញថា ការកើនឡើងនៃចំនួនអង្គភាពសេដ្ឋកិច្ចដែលមានកម្មសិទ្ធិកាន់កាប់ទីកន្លែងអាជីវកម្មនៅឆ្នាំ២០១១ គឺមានអត្រារួមចំណែកប្រមាណ ៦៧,៨% នៃចំនួនអង្គភាពសេដ្ឋកិច្ចទាំងអស់ដែលវាមានអត្រាកម្រិតខ្ពស់ផងដែរ។

## ៧. "ទីតាំងមូលដ្ឋានអាជីវកម្មនៃអង្គភាពសេដ្ឋកិច្ច" ដែលមានក្រឡាផ្ទៃទំហំធំជាង១០ម៉ែត្រការ៉េ មានប្រមាណ ៦១,០%

បើពិនិត្យលើទំហំនៃទីតាំងមូលដ្ឋានអាជីវកម្មរបស់អង្គភាពសេដ្ឋកិច្ច ដែលមានក្រឡាផ្ទៃធំជាង១០ម៉ែត្រការ៉េ មានប្រមាណជិត ៦១,០% នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប។ ទិន្នន័យលទ្ធផលជំរឿននេះ បង្ហាញថាអំពីទំហំនៃទីកន្លែងអាជីវកម្មមានការកើនឡើងចាប់តាំងពីឆ្នាំ២០១១ ដែលក្នុងនោះ អង្គភាពសេដ្ឋកិច្ចមានតិចជាង ៥០,០% ដែលមានទំហំផ្ទៃក្រឡានៃទីកន្លែងអាជីវកម្មតូចជាង១០ម៉ែត្រការ៉េ។ នៅខណៈពេលដូចគ្នានេះដែរ អង្គភាពសេដ្ឋកិច្ចដែលមានទំហំទីកន្លែងអាជីវកម្មចាប់ពី១០០ម៉ែត្រការ៉េ មានប្រមាណ ១២,០% នៅឆ្នាំ២០២២ ដែលបានកើនឡើងអត្រាប្រមាណ ៥,០% បើធៀបនឹងកំណើនតាមអត្រាប្រមាណ ៧,២% នៅឆ្នាំ២០១១ (មើលតារាង១-៨)។

## ៨. "អាជីវកម្មលក់ដុំ និងលក់រាយ និងជួសជុលយានយន្ត និងទោចក្រយានយន្ត" មានប្រមាណជិត ៦៦,០% នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប

ចំនួនអង្គភាពសេដ្ឋកិច្ច បែងចែកតាមចំណាត់ថ្នាក់វិស័យឧស្សាហកម្មស្តង់ដារអន្តរជាតិជំនាន់ទី៤(ISIC Rev4) របស់អង្គការសហប្រជាជាតិ បានបង្ហាញថាវិស័យផ្នែក "អាជីវកម្មលក់ដុំ និងលក់រាយ និងជួសជុលយានយន្ត និងទោចក្រយានយន្ត" (ផ្នែក G) មានចំនួនអង្គភាពសេដ្ឋកិច្ចច្រើនបំផុតចំនួនប្រមាណ ៤៩៤.៥៥២ សហគ្រាស ស្មើនឹង ៦៥,៦% នៃអង្គភាពសេដ្ឋកិច្ចសរុប។ ចំនួនអង្គភាពសេដ្ឋកិច្ចមានចំណែកភាគច្រើនបន្ទាប់ គឺស្ថិតក្នុងវិស័យ (ផ្នែក I ) "សកម្មភាពស្នាក់នៅ និងសេវាកម្មម្ហូបអាហារ" មានប្រមាណ ១០៦.៩៧៧ សហគ្រាស ស្មើនឹង ១៤,២% នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប ដោយបញ្ចូលរួមទាំងផ្នែក "សកម្មភាពសេវាកម្មភោជនីយដ្ឋាន និងអាហារចល័ត" (លេខកូដ៥៦១០) និង "សកម្មភាពផលិតនិងកម្មន្តសាល" (ផ្នែក C) មានប្រមាណ ៥០.០២៨ សហគ្រាស ស្មើនឹង ៦,៦% នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប។ វិស័យផ្នែកសកម្មភាពសេវាកម្មផ្សេងទៀត (ផ្នែក S) មានប្រមាណ ៥២.៣៧៨ សហគ្រាស ស្មើនឹង ៦,៩% ដោយបញ្ចូលរួមទាំងផ្នែក "សកម្មភាពកែសម្ផស្សផ្សេងៗ និងអ៊ុតសក់ កាត់សក់" (លេខកូដ៩៦០២) និងផ្នែក "សកម្មភាព សេវាសុខាភិបាល និង កិច្ចការសង្គម" (ផ្នែក Q) មានប្រមាណ ១២.២២០ សហគ្រាស ស្មើនឹង ១,៦% បញ្ចូលរួមទាំងផ្នែកសកម្មភាព "វេជ្ជសាស្ត្រ និងទន្តសាស្ត្រ" (លេខកូដ៨៦២០) សកម្មភាពមន្ទីពេទ្យ (លេខកូដ៨៦១០) និង "សកម្មភាពការសិក្សាអប់រំ" (ផ្នែក P) មានប្រមាណ ១២.២៨៣ សហគ្រាស ស្មើនឹង ១,៦% ដែលនាំមុខដោយការអប់រំកម្រិតបឋម និងថ្នាក់មតេយ្យសិក្សា(លេខកូដ៨៥៥០) (មើលតារាង ២.១.១ និង តារាង ២.១០)។

ផ្អែកតាមលទ្ធផលជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ ចំនួនអ្នកចូលរួមការងារ បែងចែកតាមចំណាត់ថ្នាក់វិស័យឧស្សាហកម្មស្តង់ដារអន្តរជាតិជំនាន់ទី៤ (ISIC Rev4) បានបង្ហាញថា វិស័យសកម្មភាពមានភាគចំណែកធំបំផុត គឺ "វិស័យឧស្សាហកម្មកម្មន្តសាល" (ផ្នែក C) ដែលមាន ១.១១៦.៦៧១ អង្គភាពសេដ្ឋកិច្ច ស្មើនឹង ៣៧,៥% នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប ដែលក្នុងនោះ វិស័យនាំមុខមានផ្នែក "សំលៀកបំពាក់ លើកលែងតែសំលៀកបំពាក់ធ្វើពីរោមសត្វ" (លេខកូដ១៤១០) "ស្បែកជើង" (លេខកូដ១៥២០) និង "ការបូបដាក់សំលៀកបំពាក់ កាបូបដៃ និងផលិតផលដូចគ្នានេះ(លេខកូដ១៥១២)"។ ផ្អែកលើទិន្នន័យលទ្ធផលជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ បង្ហាញឱ្យដឹងថា វិស័យផ្នែកឧស្សាហកម្មកម្មន្តសាលត្រូវបានរួមចំណែកគួរឱ្យកត់សម្គាល់ពីនិយោជក (ឬម្ចាស់អង្គភាពសេដ្ឋកិច្ច) នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ វិស័យសកម្មភាពមានភាគចំណែកធំទីពីរ គឺផ្នែក "អាជីវកម្មលក់ដុំ និងលក់រាយ និងជួសជុលយានយន្ត និងទោចក្រយានយន្ត" (ផ្នែក G) ដែលមានអ្នកចូលរួមការងារចំនួន ៩២០.៦៧៤ នាក់ ស្មើនឹង ៣០,៩% នៃអ្នកចូលរួមការងារសរុប។ វិស័យសកម្មភាពបន្ទាប់ទៀតគឺផ្នែក "សកម្មភាពផ្នែកស្នាក់នៅ និងសេវាចំណីអាហារ" (ផ្នែក I) មានចំនួន ២៨៧.៤៨៦នាក់ ស្មើនឹង ៩,៦% និង ផ្នែក "សកម្មភាពអប់រំ" (ផ្នែក P) មានប្រមាណ ២០៩.៣៣០ នាក់ ស្មើនឹង ៧,០% និងផ្នែកសកម្មភាពសេវាកម្មផ្សេងៗទៀត(ផ្នែក S) មានប្រមាណ ១១២.១៥៩ នាក់ ស្មើនឹង ៣,៨% (មើលតារាង ១២.១០.១)។

